# កម្ពុជា

## យុទ្ធសាស្ត្រជំនួយសំរាប់ប្រទេស
## របស់ធនាគារពិភពលោក

### របាយការណ៍វឌ្ឍនភាព



ភាពជាដៃគូក្នុងការអភិវឌ្ឍ

ដើម្បីជួយប្រទេសកម្ពុជា

អោយទទួលបានគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់ខ្លួន

ខែ មេសា ឆ្នាំ ២០០៨

**ក្រុមធនាគារពិភពលោក**

អនុប្រធានប្រចាំតំបន់ : លោក ជេមស៍ ដាប់ប៊ីលយូ អាដាមស៍
នាយកប្រចាំប្រទេស : លោក អៀន ស៊ី ផតធើរ
ប្រធានគ្រប់គ្រងប្រចាំប្រទេស: ស្ទីហ្វិន ហ្គីមប៊ើត (ស្តីទី)
ប្រធានក្រុមការងារ : ម៉ារីយ៉ា អ៊ីយ៉ូណាតា
ក្រុមការងារ : ហ្សាហ្វា អាម៉េត មែកឌី អាមីន លូវីស បេនវេនីស ប៊ូវ៉ាន់ បាតណាហ្គា នីតាយ៉ា ឆាត់ណាន់តាវេជ ហ្វូត ជា ទីម៉ូធី ខន់វេ ឡូរ៉េតតា ដ័រមែន ស្ទីហ្វិន ហ្គីមប៊ើត មីយ៉ា ហ៊ីយ៉ាន់ ភីតធើរ ជីប ហ្ស៊ី លី ញៀ មេរីក ភីតធើរ មើហ្វី ឆាលស៍ ណីឌ័រ ស៊ីន ហ្វូង វ៉ុង

# ពាក្យបំព្រួញ និងអក្សរកាត់

| | |
|---|---|
| AAA | សកម្មភាពវិភាគ និងផ្ដល់យោបល់ |
| ACWG | ក្រុមការងារប្រឆាំងនឹងអំពើពុករលួយ |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| APR | របាយការណ៍រីកចំរើនប្រចាំឆ្នាំ |
| AusAID | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី |
| C/SC | ក្រុមប្រឹក្សាឃុំ/សង្កាត់ |
| CAE | ការវាយតំលៃលើជំនួយអភិវឌ្ឍន៍ប្រទេស |
| CAR | ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល |
| CAS | យុទ្ធសាស្ត្រជំនួយអភិវឌ្ឍន៍ប្រទេស (ធនាគារពិភពលោក) |
| CDCF | វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា |
| CG | ក្រុមពិគ្រោះយោបល់ |
| CGA | ការវាយតំលៃយេនឌ័រនៅកម្ពុជា |
| CIDA | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា |
| CMDG | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា |
| CPIA | ការវាយតំលៃលើគោលនយោបាយថ្នាក់ប្រទេសនិងស្ថាប័ន |
| CPP | គណៈបក្សប្រជាជនកម្ពុជា |
| CPPR | ការពិនិត្យមើលឡើងវិញលើការអនុវត្តផលប័ត្រថ្នាក់ប្រទេស |
| CSES | ការស្ទាបស្ទង់លើសេដ្ឋកិច្ចសង្គមរបស់កម្ពុជា |
| DFGG | តំរូវការសំរាប់អភិបាលកិច្ចល្អ |
| DFID | នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ (ចក្រភពអង់គ្លេស) |
| DP | ដៃគូអភិវឌ្ឍន៍ |
| EC | សហគមន៍អឺរ៉ុប |
| EFA | ការអប់រំសំរាប់ទាំងអស់គ្នា |
| EITI | គំនិតផ្ដួចផ្ដើមស្ដីអំពីតម្លាភាពក្នុងឧស្សាហកម្មទីស្សារណេកម្ម |
| ELC(s) | សម្បទានដីសង្គមកិច្ច |
| ESW | ការងារសេដ្ឋកិច្ចនិងតាមវិស័យ |
| FCCPP | គំរោងសម្បទានព្រៃឈើ និងត្រួតពិនិត្យសាកល្បង |
| FDI | វិនិយោគទុនផ្ទាល់ពីបរទេស |
| FR | ការពិនិត្យមើលឡើងវិញលើការប្រើប្រាស់ថវិកាឱ្យចំគោលដៅ |
| FTI | គំនិតផ្ដួចផ្ដើមធ្វើឱ្យសំរេចការអប់រំបានឆាប់ |
| FY | ឆ្នាំសារពើពន្ធ |
| GAC | អភិបាលកិច្ច និងការប្រឆាំងអំពើពុករលួយ |
| GDCC | គណកម្មាធិការសម្របសម្រួលម្ចាស់ជំនួយ និង រដ្ឋាភិបាល |
| GDP | ផលិតផលសរុបក្នុងស្រុក |
| GGFs | ក្របខ័ណ្ឌអភិបាលកិច្ចល្អ |
| GMS | មហាអនុតំបន់មេគង្គ |
| GSP | ប្រព័ន្ធអនុគ្រោះទូទៅ |
| HRMIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស |
| ICA | ការវាយតំលៃលើបរិយាកាសវិនិយោគ |
| IDA | សមាគមអភិវឌ្ឍន៍អន្តរជាតិ |
| IDF | មូលនិធិអភិវឌ្ឍន៍អន្តរជាតិ |
| IFAPER | ការពិនិត្យមើលឡើងវិញលើការប្រើប្រាស់ថវិកាឱ្យចំគោលដៅចំរុះ និងចំណាយសាធារណៈ |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| INT | ផ្នែកសុក្រិតស្ថាប័ន |
| IPA | ទីភ្នាក់ងារលទ្ធកម្មអន្តរជាតិ |
| JBIC | ធនាគារសាជីវកម្មអន្តរជាតិជប៉ុន |
| JMI(s) | សូចនាករតាមដានរួម |
| JSDF | មូលនិធិអភិវឌ្ឍន៍សង្គមរបស់ប្រទេសជប៉ុន |
| LASED | ការបែងចែកដីធ្លីសំរាប់សង្គមកិច្ច និងដើម្បីអភិវឌ្ឍសេដ្ឋកិច្ច |
| LICUS | ប្រទេសដែលមានប្រាក់ចំណូលទាបក្រោមសម្ពាធ |
| LMAP | គំរោងគ្រប់គ្រងដីធ្លីនិងរដ្ឋបាល |
| M&E | ត្រួតពិនិត្យ និងការវាយតំលៃ |
| MBPI | គំនិតផ្ដួចផ្ដើមនៃប្រាក់លាភការដោយផ្អែកលើលទ្ធផលការងារ |
| MDG | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ |

| | |
|---|---|
| MDTF | មូលនិធិមរតករបស់ពហុម្ចាស់ជំនួយ |
| MEF | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| MoH | ក្រសួងសុខាភិបាល |
| MONASRI | ក្រសួងទំនាក់ទំនងសភាព្រឹទ្ធសភានិងអធិការកិច្ច |
| MoP | ក្រសួងផែនការ |
| MoWVA | ក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន |
| MPDF | សេវាកម្មអភិវឌ្ឍន៍វិស័យឯកជនមេគង្គ |
| NA | រដ្ឋសភាជាតិ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NRM | ការគ្រប់គ្រងធនធានធម្មជាតិ |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ODA | ជំនួយអភិវឌ្ឍន៍ផ្លូវការ |
| OED | នាយកដ្ឋានវាយតំលៃប្រតិបត្តិការ |
| PA | តំបន់ការពារធម្មជាតិ |
| PAR | កំណែទំរង់រដ្ឋបាលសាធារណៈ |
| PBA | អភិក្រមតាមកម្មវិធី |
| PETS | ការស្ទាបស្ទង់លើការតាមដានចំណាយសាធារណៈ |
| PFM | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PFMAP | គំរោងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងគណនេយ្យភាព |
| PFMRP | កម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PHRD | ភាពក្រីក្រនិងការអភិវឌ្ឍធនធានមនុស្ស |
| PPI | ការចូលរួមរបស់ផ្នែកឯកជនក្នុងការស្តារហេដ្ឋារចនាសម្ព័ន្ធ |
| PRGO | ការកាត់បន្ថយភាពក្រីក្រ និងប្រតិបត្តិការកំណើន |
| PSD | ការអភិវឌ្ឍវិស័យឯកជន |
| PSIA | ការវិភាគលើភាពក្រីក្រនិងផលប៉ះពាល់សង្គម |
| RAMP | គំរោងគ្រប់គ្រងផ្លូវថ្នល់ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RILGP | គំរោងវិនិយោគជនបទនិងអភិបាលកិច្ចមូលដ្ឋាន |
| RS | យុទ្ធសាស្ត្រចតុកោណ |
| SAD | ឯកសាររដ្ឋបាលទោល |
| SIDA | ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសស៊ុយអែត |
| SME | សហគ្រាសខ្នាតតូចនិងមធ្យម |
| SNEC | ក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិជាន់ខ្ពស់ |
| SWAp | អភិក្រមក្របដណ្តប់លើវិស័យ |
| TA | ជំនួយបច្ចេកទេស |
| TOR(s) | លក្ខខណ្ឌតំរូវការ |
| TWG | ក្រុមការងារបច្ចេកទេស |
| UN | អង្គការសហប្រជាជាតិ |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |

# មាតិកា

I. សេចក្តីផ្តើម និងការផ្លាស់ប្តូរនៅក្នុងបរិបទប្រទេស.....1

II. ការរីកចំរើនក្នុងការអនុវត្ត.....2

ក. ការរីកចំរើនលើគោលបំណងរបស់CAS.....3

ខ. ភាពជាដៃគូ និងរបៀបវារៈនៃប្រសិទ្ធិភាពជំនួយ.....6

គ. យន្តការនិងការអនុវត្តនៅថ្នាក់គំរោង.....8

ឃ. មេរៀនដែលទទួលបាន.....11

III. ពង្រឹងនិងពង្រីកកម្មវិធីCAS.....12

IV. ការគ្រប់គ្រងហានិភ័យ.....17

## អត្ថបទក្នុងប្រអប់

ប្រអប់ ១ : ការកាត់បន្ថយភាពក្រីក្រ និងប្រតិបត្តិការកំណើន

ប្រអប់ ២ : ការដោះស្រាយបញ្ហាអំពើពុករលួយនៅក្នុងគំរោង

ប្រអប់ ៣ : គំរោងគំរូវការសំរាប់អភិបាលកិច្ចល្អ (DFGG)

## ឯកសារភ្ជាប់ជាមួយ

ឯកសារភ្ជាប់ ១ : វឌ្ឍនភាពលើការអនុវត្តឆ្ពោះទៅរកគោលបំណងរបស់ CAS

# I. សេចក្តីផ្តើម និងការផ្លាស់ប្តូរនៅក្នុងបរិបទប្រទេស

**១. *របាយការណ៍នេះ រាយការណ៍ថ្មីចុងក្រោយជូនក្រុមប្រឹក្សាភិបាលអំពីការរីកចំរើនក្នុងការអនុវត្តយុទ្ធសាស្ត្រជំនួយអភិវឌ្ឍន៍ប្រទេស (CAS ) សំរាប់កម្ពុជា (របាយការណ៍លេខ ៣២១១៨-KH) សំរាប់ឆ្នាំសារពើពន្ធ ២០០៥-២០០៨។*** *របាយការណ៍នេះ ស្របគ្នាទាំងស្រុងទៅនឹងយុទ្ធសាស្ត្រតំបន់អាស៊ីបូព៌ា*[១] *និងឆ្លុះបញ្ចាំងអំពីការងារដែលបានពិពណ៌នានៅក្នុងយុទ្ធសាស្ត្រនោះ ក្នុងការគាំទ្រដល់ការពង្រឹងការងារអភិវឌ្ឍន៍ដើម្បីសន្តិភាព ភាពរីកចំរើន និងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសក្រីក្រជាងគេបំផុត និងប្រទេសដែលទន់ខ្សោយជាងគេបំផុតនៅក្នុងតំបន់។*

**២. *នៅពេលដែលនាយកប្រតិបត្តិ បានអនុម័ត CAS សំរាប់កម្ពុជានៅក្នុងឆ្នាំ ២០០៥ កម្ពុជាស្ថិតនៅក្នុងចំណោមប្រទេសក្រីក្រជាងគេបំផុតនៅលើពិភពលោកនៅឡើយ ដែលមានចំណូលសំរាប់មនុស្សម្នាក់ស្មើ ៤៣០ ដុល្លា ទោះបីជាមានកំណើនខ្ពស់រយៈពេលជិតមួយទសវត្សរ៍ក៏ដោយ។*** ទោះបីជាមានការខ្វះទិន្នន័យសំរាប់ធ្វើការកំណត់អំពីនិន្នាការទាំងនេះក្តី ក៏អត្រាភាពក្រីក្រ ត្រូវបានគេដឹងថាមានកំរិតខ្ពស់ ហើយនិងសូចនាករសង្គមមិនល្អ។ ស្ថាប័នសាធារណៈជាច្រើនដែលអាចជួយដោះស្រាយបញ្ហាទាំងនេះបាន ត្រូវបានបំផ្លាញចោលក្នុងកំឡុងពេលជំលោះ ដែលមានរយៈពេលបីទសវត្សរ៍ ហើយស្ថាប័នទាំងនេះកំពុងត្រូវបានកសាងឡើងវិញ និងការងារវិភាគលើអភិបាលកិច្ច គឺជាបញ្ហាលំបាកចំបងចំពោះការកាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តភាព។ វាស្ថិតនៅក្នុងបរិបទនេះ ដែលក្រុមធនាគារពិភពលោកបានរៀបចំជាស្រេចនូវ CAS ដែលផ្តោតទៅលើអភិបាលកិច្ចដែលត្រូវបានរៀបចំរួមគ្នាដោយ ADB, DFID និងបណ្តាអង្គការរបស់សហប្រជាជាតិ ដែលបង្កើតបាននូវ CAS រួមលើកដំបូងរបស់ក្រុមធនាគារពិភពលោក។

**៣. *ចាប់តាំងពីពេលនោះមកកម្ពុជាបានបន្តផ្លាស់ប្តូរជាច្រើន ហើយចំណេះដឹងមូលដ្ឋានមានការរីកចំរើនយ៉ាងច្រើន។*** កម្ពុជា ទទួលបាននូវកំណើនទ្វេដងនៅក្នុងឆ្នាំ ២០០៤-២០០៦ និងកើនឡើង១០ភាគរយនៅក្នុងឆ្នាំ ២០០៧ ដែលលើសពីការព្យាករណ៍ទុក។ កំណើនសេដ្ឋកិច្ចដ៏ខ្លាំងនេះ គឺកើនឡើងដោយសារការនាំចេញសំលៀកបំពាក់ ការកើនឡើងនៃវិស័យទេសចរណ៍ សំណង់ និងស្ថេរភាពនៃវិស័យកសិកម្ម។ បច្ចុប្បន្ន អត្រានៃភាពក្រីក្រ ត្រូវបានគេទទួលស្គាល់ថា បានធ្លាក់ចុះពីចន្លោះ ៤៥-៥០ភាគរយមកនៅ ៣៥ភាគរយ នៅក្នុងឆ្នាំ ២០០៤ ក្នុងកំឡុងពេលមួយទសវត្សរ៍ថ្មីៗនេះ។ វិសមភាពនៃការប្រើប្រាស់មានស្ថេរភាពក្នុងចន្លោះពីឆ្នាំ ១៩៩៧ ដល់ ២០០៤ ក្រោយពីមានការកើនឡើងពីឆ្នាំ ១៩៩៤-១៩៩៧ ហើយត្រូវបានគេរំពឹងទុកថា ភាពក្រីក្រ បានថយចុះបន្ថែមទៀតនៅក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយ ដោយសារវិស័យកសិកម្មមានការកើនឡើងខ្លាំង។ កម្ពុជាក៏មានការរីកចំរើនគួរឱ្យកោតសរសើរផងដែរ លើវិស័យសង្គមកិច្ច។ អត្រាចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សាសរុបបានកើនឡើងលឿនជាងប្រទេសដែលមានចំណូលទាបនានា គិតជាមធ្យម ចំណែកឯលទ្ធផលផ្នែកសុខភាពជាច្រើនដូចជាអត្រាមេរោគអេដស៍ និងអត្រាស្លាប់របស់កុមារ មានការរីកចំរើនគួរឱ្យកត់សំគាល់។

**៤. *សន្តិភាព និងស្ថេរភាពនយោបាយនៅក្នុងប្រទេសកម្ពុជា ក៏ត្រូវបានថែរក្សាផងដែរ។*** ការបោះឆ្នោតឃុំនៅក្នុងឆ្នាំ ២០០៧ បានប្រព្រឹត្តិទៅប្រកបដោយជោគជ័យ ហើយគណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាចកាន់កាប់រដ្ឋាភិបាល មូលដ្ឋាន

---

[១] *ការធានាចំពោះអនាគត : គាំទ្រដល់ការបែងចែកនិងចិរភាពនៃកំណើននៅក្នុងប្រទេសក្នុងតំបន់អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក និងផ្សេងទៀត SecM2008-0152, April 10, 2008*

ទោះបីជា គណបក្សសម រង្ស៊ី ដែលជាបក្សប្រឆាំងទទួលបានជោគជ័យគួរអោយកត់សំគាល់ក្នុងការបោះឆ្នោតនេះក៏ដោយ។ ការបោះឆ្នោតជាតិ គ្រោងនឹងធ្វើឡើងនៅខែកក្កដា ឆ្នាំ ២០០៨ ខាងមុខ។ ក្រៅពីនេះ ការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម បានចាប់ផ្តើមដំណើរការនៅក្នុងឆ្នាំ ២០០៧ ហើយអតីតមន្ត្រីខ្មែរក្រហមមួយចំនួន ឥឡូវនេះកំពុងប្រឈមមុខទៅនឹងការកាត់ទោសពីការ ចោទប្រកាន់ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

***៥. ក៏ប៉ុន្តែ កម្ពុជានៅតែប្រឈមមុខទៅនឹងកំណែទំរង់រចនាសម្ព័ន្ធដែលមានលក្ខណៈលំបាកខ្លាំង និងបញ្ហាអភិបាលកិច្ច។*** ឧទាហរណ៍ ខណៈដែលកំណើនកើនឡើងខ្ពស់ មូលដ្ឋាននៃកំណើន នៅតែមានលក្ខណៈតូចចង្អៀតនិងមិនមានលក្ខណៈបែងចែក ដែលផ្នែកសំលៀកបំពាក់ នៅតែមានចំនួនច្រើនជាង ៨០ ភាគរយ នៃចំណូលពីការនាំចេញ។ ការប្រកួតប្រជែងកាន់តែខ្លាំងពីបណ្តាប្រទេសជិតខាង អាចនឹងមានផលប៉ះពាល់អវិជ្ជមានចំពោះអត្រាកំណើនដ៏ខ្ពស់នេះ។ តំលៃស្បៀង និងថាមពលដែលកំពុងកើនឡើងយ៉ាងលឿន ក៏មានការគំរាមកំហែងធ្វើឱ្យប៉ះពាល់ដល់កំណើន និងការកាត់បន្ថយភាពក្រីក្រផងដែរ។ ចំណូលរបស់រដ្ឋាភិបាល មានការកើនឡើង ក៏ប៉ុន្តែ ចំណូលចំពោះសមមាត្រនៃផលិតផលសរុបក្នុងស្រុក (១២ភាគរយ) នៅតែមិនគ្រប់គ្រាន់និងស្ថិតនៅក្រោមមធ្យមភាគ សំរាប់ប្រទេសដែលមានចំណូលទាបនានា។ ចំណែកឯផ្នែកសង្គមកិច្ចវិញ មានការរីកចំរើនយ៉ាងលឿនលើការចុះឈ្មោះចូលរៀនថ្នាក់បឋម ក៏ប៉ុន្តែមានកុមារតែពាក់កណ្តាលប៉ុណ្ណោះដែលបានចូលរៀនថ្នាក់បឋមបានបញ្ចប់ការសិក្សា។ ចុងក្រោយ សូចនាករសកលមួយចំនួនបង្ហាញថា អភិបាលកិច្ចនៅក្នុងប្រទេសកម្ពុជានៅតែទន់ខ្សោយនៅឡើយ។

***៦. ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ នៅក្នុងឆ្នាំ ២០០៦ រាជរដ្ឋាភិបាលកម្ពុជា (RGC) បានអនុម័តនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ដ៏សំខាន់មួយ គឺផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ដើម្បីជំនួសឱ្យយុទ្ធសាស្ត្រប្រកួតប្រជែងជាច្រើនដែលមានពីមុនមក។*** ផែនការនេះផ្សារភ្ជាប់ទស្សនៈវិស័យនៅក្នុងយុទ្ធសាស្ត្រចតុកោណ (វេទិកានយោបាយឆ្នាំ ២០០៥ របស់ RGC) ទៅនឹងគោលដៅនិងមុខព្រួញសំខាន់ៗ ហើយពឹងផ្អែកលើប៉ូល[2] ចំនួន ៦។ របកគំហើញ ចាប់តាំងពី CAS ត្រូវបានរៀបចំ ទាក់ទងទៅ នឹងបរិមាណប្រេងនិងឧស្ម័នដែលអាចយកបាននៅផ្ទៃសមុទ្រ និងរ៉ែនៅលើឆ្នេរសមុទ្រ បានកែលំអទស្សនវិស័យរយៈពេលមធ្យមសំរាប់ប្រទេសកម្ពុជា ក្នុងខណៈដែលកំពុងបង្កើនភាពបន្ទាន់នៃការដាក់ឱ្យរៀបរយនូវក្របខ័ណ្ឌសមស្របមួយសំរាប់ត្រួតពិនិត្យមើលនិងគ្រប់គ្រងធនធានធម្មជាតិ។ ការប៉ាន់ប្រមាណចុងក្រោយថ្មីៗនេះរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានព្យាករណ៍កំណើនថាមានប្រហែល ៧ ភាគរយក្នុងមួយឆ្នាំៗសំរាប់រយៈពេល ៣ ឆ្នាំខាងមុខ។ ការប៉ាន់ប្រមាណនេះស្របទៅតាមសក្តានុពលកំណើនរបស់ប្រទេស និងរួមទាំងផលប៉ះពាល់នៃថាមពលនិងតំលៃស្បៀង ដែលកើនឡើងកាន់តែខ្ពស់ និងការកើនឡើងនៃការប្រកួតប្រជែង នៅក្នុងវិស័យនាំចេញសំខាន់ៗរបស់កម្ពុជា។ តាមការពិត បញ្ហាប្រឈមចំបងចំពោះសេដ្ឋកិច្ច គឺពង្រីកប្រភពនៃកំណើនរបស់ខ្លួន និងដាក់ជាគោលបំណងសំខាន់របស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

## II. ការរីកចំរើនលើការអនុវត្ត

***៧. នៅក្នុងការអនុវត្តរយៈពេលជិត ៣ ឆ្នាំ មានការរីកចំរើនគួរឱ្យកត់សំគាល់ ក្នុងការសំរេចបាននូវលទ្ធផលរំពឹងទុកជាច្រើនរបស់ CAS ទោះបីជាការអនុវត្តនេះ មានការយឺតយ៉ាវ ដោយសារតែមានបញ្ហាមួយចំនួនដែលរកមិន***

---

[2] អភិបាលកិច្ចល្អ - ការថែរក្សាស្ថេរភាពនយោបាយនិងម៉ាក្រូសេដ្ឋកិច្ច និងភាពជាដៃគូរឹងមាំជាមួយភាគីពាក់ព័ន្ធទាំងអស់ - លើកកំពស់វិស័យកសិកម្ម - បន្តការស្តារឡើងវិញនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត - កំណើននិងការងារវិស័យឯកជន - និង ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស។

***ទាន់ឃើញនៅក្នុងគំរោងជាច្រើនដែលគាំទ្រដោយធនាគារពិភពលោកក៏ដោយ ។*** ការពិនិត្យមើលឡើងវិញលើប្រភេទនៃសូចនាករមធ្យមនៃការរីកចំរើនរបស់ CAS (ឯកសារភ្ជាប់ ២) បង្ហាញថា ៣0 ភាគរយនៃសូចនាកររីកចំរើន ១៣៤ ត្រូវបានបញ្ចប់ និង៤៣ ភាគរយបន្ថែមទៀតកំពុងតែបន្ត ។ ការកំណត់ចំណាត់ថ្នាក់លើការវាយតំលៃស្ថាប័ន និងគោលនយោបាយប្រទេស (CPIA) សំរាប់កម្ពុជាក៏មានការកើនឡើងពី ៣,0 នៅក្នុងឆ្នាំ ២00៤ ដល់ ៣,២ នៅក្នុងឆ្នាំ ២00៧ ។ ក៏ប៉ុន្តែ ច្បាស់ណាស់ដែលថា ការរីកចំរើនទាក់ទងទៅនឹងប៉ូលអភិបាលកិច្ចរបស់ CAS មានលក្ខណៈយឺតយ៉ាវជាងកំណើនទាក់ទងទៅនឹងការគាំទ្រដល់ យុទ្ធសាស្ត្រជាតិ និងកម្មវិធីវិនិយោគ ដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៏សហវត្សរ៏កម្ពុជា (CMDG) ។ ទាក់ទងទៅនឹងលក្ខណៈសំខាន់ៗដទៃទៀតរបស់ CAS ដូចជាការធ្វើការតាមរយៈភាពជាដៃគូយុទ្ធសាស្ត្រ និងការកាត់បន្ថយហានិភ័យនៃទំនុកចិត្តមានការរីកចំរើនគួរឱ្យកត់សំគាល់លើរបៀបវារៈផ្តល់ជំនួយដែលមានប្រសិទ្ធិភាព និងលើការពង្រឹងភាពជាដៃគូ និងទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធដទៃទៀត ។ ដើម្បីកាត់បន្ថយហានិភ័យនៃទំនុកចិត្ត RGC និងធនាគារពិភពលោក បានយល់ព្រមដើម្បីពង្រឹងការត្រួតពិនិត្យគំរោង (សូមមើលកថាខ័ណ្ឌទី ២២-២៣ និង ៣0) បន្ទាប់ធនាគារពិភពលោក បានប្រកាសអំពីកំហុសឆ្គងលទ្ធកម្មនៅក្នុងខែមិថុនា ឆ្នាំ ២00៦ ហើយបានផ្អាកការបញ្ចេញប្រាក់រយៈពេល ៨ ខែ សំរាប់គំរោងចំនួនបី ។ ការផ្អាកនេះ រួមជាមួយនឹងការជំទាស់របស់ RGC លើដំណើរការស៊ើបអង្កេត (និងយុទ្ធវិធីក្នុងការចែក ព័ត៌មានអំពីភស្តុតាងនៃអំពើពុករលួយ) បានឈានទៅដល់រយពេលដ៏តឹងតែង ដើម្បីធ្វើកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់មួយជាមួយរដ្ឋាភិបាលប្រកបដោយមានប្រសិទ្ធិភាព ។ ក៏ប៉ុន្តែការអនុវត្តកម្មវិធី មិនមានផលប៉ះពាល់ គួរឱ្យកត់សំគាល់នោះទេ ដោយហេតុថាគំរោងដែលត្រូវបានផ្អាកធ្វើឡើងដើមទីនៃការអនុវត្ត ហើយសកម្មភាពរបស់គំរោងមិនបានបញ្ឈប់ទាំងស្រុងនោះទេ ពីព្រោះកិច្ចសន្យាមិនទាន់ត្រូវបានបញ្ចប់នៅឡើយ ។

## គ. ការរីកចំរើនលើការអនុវត្ត CAS

***៨. ប៉ូលទី ១ របស់ CAS លប់បំបាត់នូវបញ្ហាលំបាកនៃអភិបាលកិច្ច ដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហវត្សរ៏កម្ពុជា ដែលផ្តោតទៅលើគោលបំណងចំនួន ៤ :*** (១) ជំរុញការអភិវឌ្ឍវិស័យឯកជនដើម្បីកាត់បន្ថយភាពក្រីក្រ (២) កែលំអការគ្រប់គ្រងធនធានធម្មជាតិ (៣) កែលំអការផ្គត់ផ្គង់សេវាកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង(៤) គាំទ្រដល់វិមជ្ឈការ និងជំរុញភាពជាដៃគូរបស់ពលរដ្ឋសំរាប់អភិបាលកិច្ចល្អ ។ គោលបំណងទាំងបួននេះ ត្រូវបានជ្រើសរើស ដោយសារតែវាមានសារៈសំខាន់ចំពោះកំណើន និងការកាត់បន្ថយភាពក្រីក្រ ព្រមទាំងភាពជាម្ចាស់និងភាពជាអ្នកដឹកនាំដ៏រឹងមាំពីរដ្ឋាភិបាល ។ ការជ្រើសរើសនេះ ក៏ត្រូវបានជំរាបជូនផងដែរតាមរយៈមេរៀន ទទួលបានពីភាពជោគជ័យ និងបរាជ័យ នៅក្នុងយុទ្ធសាស្ត្រនានាកន្លងទៅ និងតាមរយៈ អត្ថប្រយោជន៏ប្រៀបធៀបរបស់ដៃគូអភិវឌ្ឍន៏នានា ។ ការរីកចំរើនលើប៉ូលទី១នៃគោលបំណងរបស់ CAS មានលក្ខណៈចំរុះដែល ៥0 ភាគរយ នៃសូចនាករមធ្យមត្រូវបានបញ្ចប់ ឬលើកន្លងត្រឹមត្រូវ ។ កំណើនលើគោលបំណងនីមួយៗត្រូវបានសង្ខេបដូចខាងក្រោម និងពិពណ៌នាពិស្តារនៅក្នុងឯកសារភ្ជាប់ទី១ ។

***៩. ការរីកចំរើនលើកិច្ចប្រឹងប្រែងរបស់ក្រុមធនាគារពិភពលោក ក្នុងការជំរុញការអភិវឌ្ឍវិស័យឯកជនដើម្បីកាត់បន្ថយភាពក្រីក្រ*** មានលក្ខណៈចំរុះ គឺ ៥0 ភាគរយ នៃសូចនាករត្រូវបានបញ្ចប់ ឬលើកន្លងត្រឹមត្រូវ ។ ការគាំទ្រលើផ្នែកនេះ រួមមានការងារសម្របសម្រួលពាណិជ្ជកម្ម ដែលមានការរីកចំរើនថេរលើកម្មវិធីកំណត់ពន្ធគយស្វ័យប្រវត្តិ (ASYCUDA) និងការអនុម័តច្បាប់ពន្ធគយ ។ ច្បាប់សំរាប់កែលំអក្របខ័ណ្ឌច្បាប់សំរាប់ការវិនិយោគ និងការអភិវឌ្ឍវិស័យឯកជន ក៏ត្រូវបានអនុម័តផងដែរ ក៏ប៉ុន្តែការអនុវត្តមានការយឺតយ៉ាវ ។ ធនាគារពិភពលោក បានគាំទ្រកំណែទំរង់គោលនយោបាយនៅក្នុងផ្នែកទាំងនេះ តាម

**ប្រអប់ ១ : ប្រតិបត្តិការកាត់បន្ថយភាពក្រីក្រ និងកំណើន**

**ដៃគូអភិវឌ្ឍន៍ (DP) មួយក្រុមដឹកនាំដោយធនាគារពិភពលោក បានចូលរួមជាមួយរដ្ឋាភិបាលលើប្រតិបត្តិការគោលនយោបាយអភិវឌ្ឍន៍មួយស៊េរី។** ក្រុមប្រឹក្សាភិបាលបានអនុម័តជាលើកដំបូងនូវប្រតិបត្តិការកាត់បន្ថយភាពក្រីក្រនិងកំណើន (PRGO) ដែលមានទឹកប្រាក់ចំនួន ១៥ លានដុល្លារអាមេរិក នៅខែ កក្កដា ឆ្នាំ ២០០៧ ហើយលើកទី ២ កំពុងពិភាក្សានាពេលនេះ។

PRGOs **គាំទ្រដល់ការអនុវត្ត** NSDP **តាមរយៈគោលបំណងជាក់លាក់ចំនួនបី។** ទីមួយ PRGOs គាំទ្រកម្មវិធីកំណែទំរង់មួយសំដៅធ្វើឱ្យមានការរីកចំរើន និងកាត់បន្ថយភាពក្រីក្រ តាមរយៈការកែលំអបរិយាកាសវិនិយោគផលិតភាពកសិកម្ម កាន់តែខ្ពស់ និងការផ្គត់ផ្គង់សេវាកម្មសាធារណៈកាន់តែមានប្រសិទ្ធិភាព។ ទីពីរ PRGOs ផ្តល់នូវការគាំទ្រ ដល់របៀបវារៈកំណែទំរង់តាមរយៈការផ្តោតការយកចិត្តទុកដាក់លើការពិភាក្សាអំពីគោលនយោបាយស្តីអំពីលទ្ធផលនិងសមិទ្ធផលដែលទទួលបាន។ វាក៏ពឹងផ្អែកផង ដែរលើកំលាំងនៃការធ្វើកំណែទំរង់ ដែលឱកាសនយោបាយកើតមាន។ ចុងបញ្ចប់ PRGOs គឺជាយានជំនិះមួយសំរាប់ដៃគូអភិវឌ្ឍន៍ ដើម្បីធ្វើសុខដុមណីយកម្ម និងរៀបចំតួនាទីគោលនយោបាយរបស់ខ្លួន ពឹងផ្អែកលើក្របខ័ណ្ឌពិនិត្យតាមដានដែលបានព្រមព្រៀង នៅថ្នាក់វិស័យ និងផ្តល់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ការអនុវត្ត NSDP ជារួម។

**ក្នុងពេលនេះ** PRGOs **ត្រូវបានផ្តល់ហិរញ្ញប្បទានរួមគ្នាដោយដៃគូអភិវឌ្ឍន៍ចំនួនបួន ដែលកំពុងធ្វើការក្នុងភាពជាដៃគូជាមួយក្រុមដៃគូអភិវឌ្ឍន៍ធំៗជាច្រើន។** បន្ទាប់ពីប្រតិបត្តិការទីមួយត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ធនាគារពិភពលោក រដ្ឋាភិបាលជប៉ុន បានចុះហត្ថលេខាលើកម្ចី JBIC ដែលមាន ទឹកប្រាក់ ១ ពាន់លានយេន (ប្រហែល ៨,៥ លានដុល្លារអាមេរិក)។ បន្ទាប់មកសហគមន៍អឺរ៉ុប បានអនុម័តនូវថវិកាចំនួន ២២,២ លានអឺរ៉ូ សំរាប់រយៈពេលពីឆ្នាំ ២០០៧-២០១០ ដែលការដកប្រាក់ប្រចាំឆ្នាំលើកទីមួយចំនួន ៥ លានអឺរ៉ូ នៅក្នុងឆ្នាំ ២០០៧។ ចុងក្រោយអង្គការ DFID បានអនុម័តកម្មវិធីមួយដែលមានទឹកប្រាក់ ៧,៥ លានផោន សំរាប់រយៈពេលបីឆ្នាំ (បន្ថែមពីលើមូលនិធិសំរាប់ជំនួយបច្ចេកទេស ២០០.០០០ ផោនទៀត)។ ការដកប្រាក់លើកទីមួយ នឹងចាប់ផ្តើមក្នុងពេលឆាប់ៗខាងមុខ។ ក្រៅពីនេះ អង្គការ AusAID, CIDA, SIDA និងទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ប្រទេសអេស្បាញ បានចូលរួមយ៉ាងជិតស្និទ្ធនៅក្នុងដំណើរការនេះដែរ។

រយៈប្រតិបត្តិការ កាត់បន្ថយភាពក្រីក្រនិងកំណើន (សូមមើលប្រអប់ ១) និងគំរោងសម្របសម្រួលពាណិជ្ជកម្ម និងភាពប្រកួតប្រជែងដែលកំពុងជួយ ធ្វើឱ្យប្រសើរឡើងដល់ទំរង់បែបបទនៃការនាំចូល/ចេញ ព្រមទាំងកាត់បន្ថយការចំណាយលើសកម្មភាពពាក់ព័ន្ធនឹងពាណិជ្ជកម្ម។ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ក៏មានលក្ខណៈសកម្មផងដែរលើផ្នែកទាំងនេះតាមរយៈសេវាកម្មអភិវឌ្ឍន៍វិស័យឯកជនមេគង្គ (MPDF) ដែលបានរៀបចំនូវប័ណ្ណដាក់ពិន្ទុផ្នែកបរិស្ថានពាណិជ្ជកម្មតាមខេត្តនៅក្នុងខេត្តចំនួន ១០ នៅកម្ពុជា។

***១០. ការរីកចំរើនលើការកែលំអការគ្រប់គ្រងធនធានធម្មជាតិ (NRM) មានលក្ខណៈរឹងមាំ*** ដែល៦៥ ភាគរយនៃសូចនាករកំណើនត្រូវបានបញ្ចប់ ឬកំពុងបន្ត ក៏ប៉ុន្តែ នៅមានការព្រួយបារម្ភមួយចំនួន។ កម្មវិធីផ្តល់កម្មសិទ្ធិដីធ្លីរបស់ RGC ដែលគាំទ្រដោយគំរោងគ្រប់គ្រងដីធ្លី និងរដ្ឋបាល (LMAP) ទទួលបានជោគជ័យគួរឱ្យកត់សំគាល់ ដោយបានផ្តល់នូវកម្មសិទ្ធិដីធ្លី ចំនួនជាង ៨០០.០០០ នៅក្នុងរយៈពេល ៥ ឆ្នាំកន្លងទៅ។ អនុក្រិត្យស្តីអំពីការគ្រប់គ្រងដី រដ្ឋនិងស្តីពីសម្បទានដីសេដ្ឋកិច្ច (ELCs) ត្រូវបានអនុម័ត ទោះបីជាតំរូវអោយមានការកែលំអលើតម្លាភាពក្នុងការប្រកាស ELCs ក៏ដោយក៏រដ្ឋាភិបាលនាពេលថ្មីៗនេះបាន

ចេញប្រកាសច្បាប់ស្តីពីតំបន់ការពារធម្មជាតិថ្មីមួយ ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ថែមទៀតទាក់ទងទៅ នឹងតួនាទីរបស់ស្ថាប័ន ការទទួលខុសត្រូវ និងកាតព្វកិច្ច។ ដើម្បីរួមបញ្ចូលនូវកិច្ចប្រឹងប្រែងរបស់ធនាគារពិភពលោកអោយបានកាន់តែប្រសើរឡើងទាក់ទង ទៅនឹងបញ្ហាដីធ្លី ព្រៃឈើ និងការអភិរក្សជីវចំរុះ ធនាគារពិភពលោក បានបង្កើតនូវក្របខ័ណ្ឌ NRM មួយដែលព្យាយាមសង្ខេប អំពីបញ្ហាប្រឈមសំខាន់ៗ និងសកម្មភាពចាំបាច់ ដើម្បីជំរុញឱ្យរបៀបវារៈរួមដើរទៅមុខ និងបានគាំទ្រដល់កំណែទំរង់ គោលនយោបាយតាមរយៈ PRGO។ ទោះបីជាមានសមិទ្ធិផលគួរឱ្យកត់សំគាល់ទាំងនេះក៏ដោយ ក៏ការរីកចំរើនលើផ្នែកទាំងនេះ ត្រូវជួបបញ្ហាចំពោះការប្រើប្រាស់ថវិការឱ្យចំគោលដៅដែលរកឃើញនៅក្នុងគំរោងចំនួន ៤ នៅក្នុងវិស័យនេះ ហើយគំរោងមួយបន្ថែម ទៀតស្ថិតក្នុងករណីតាមដាន។

***១១. កិច្ចប្រឹងប្រែងដើម្បីកែលំអការផ្តត់ផ្គង់សេវាកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) មានលក្ខណៈគួរឱ្យពេញចិត្ត*** ដោយ ៥៧ ភាគរយនៃសូចនាករលទ្ធផលមធ្យម ត្រូវបានបញ្ចប់ ឬគន្លងត្រឹមត្រូវ។ ជោគជ័យជាច្រើន រួមមានការអនុវត្តការរៀបចំសំរាប់ការបែងចែកថវិកាដែលបានកែលំអ ដែលបានគាំទ្រតាមរយៈកម្មវិធីកែទំរង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ អភិក្រមក្របដណ្តប់លើវិស័យ(SWAP) លើកទីមួយនៅកម្ពុជា ដែលត្រូវបានទទួលស្គាល់ថាជាគំរូមួយនៃ ប្រសិទ្ធិភាពជំនួយសកល។ គំរោងថ្មីស្តីអំពីគំនិតផ្តួចផ្តើមនៃប្រាក់លាភការដោយផ្អែកលើលទ្ធផលការងារ (MBPI) ត្រូវបានអនុវត្តនៅ ក្នុងក្រសួងសេដ្ឋកិច្ចដើម្បី ដោះស្រាយបញ្ហានៃការលើកទឹកចិត្តដល់រាជការស៊ីវិលការប្រតិបត្តិការងារ និងសមត្ថភាព គឺសមិទ្ធិផលមួយ ទៀតដែលធនាគារពិភពលោកបានគាំទ្រ។ ប្រព័ន្ធនេះ បច្ចុប្បន្នកំពុងត្រូវបានពង្រីកបន្តិចម្តងៗ ទៅដល់កម្មវិធីកំណែទំរង់យុទ្ធ សាស្ត្រដែលផ្តល់ ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ទាំងអស់។ កំណែទំរង់គោលនយោបាយ PFM ក៏ត្រូវបានគាំទ្រតាមរយៈ PRGO ផងដែរ។

***១២. មានការរីកចំរើនគួរឱ្យកត់សំគាល់លើការគាំទ្រដល់ផ្នែកវិមជ្ឈការ និងលើការបង្កើនភាពជាដៃគូរបស់ ពលរដ្ឋ ដើម្បីឱ្យមានអភិបាលកិច្ចប្រសើរឡើង*** ដោយ ៧១ ភាគរយ នៃសូចនាករត្រូវបានបញ្ចប់ ឬគន្លងត្រឹមត្រូវ។ ច្បាប់ស្តី អំពីអង្គការ ត្រូវបានអនុម័តដោយរដ្ឋសភាជាតិ ក្នុងខែ មេសា ឆ្នាំ ២០០៨។ ស្របគ្នាជាមួយនឹងគោលដៅនៃការធ្វើវិមជ្ឈការធនធាន ទៅឱ្យស្ថាប័នរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន មូលនិធិជាមធ្យមសំរាប់ឃុំ/សង្កាត់ បានកើនឡើងរៀងរាល់ឆ្នាំ ចាប់តាំងពី ឆ្នាំ ២០០២ មក ហើយត្រូវបានរំពឹងថា នឹងកើនឡើងទ្វេដងលើចំនួនបច្ចុប្បន្ននៅត្រឹមឆ្នាំ ២០១០។ ធនាគារពិភពលោក បានផ្តល់នូវជំនួយឧបត្ថម្ភ ជាច្រើនសំរាប់ការងារនេះ តាមរយៈគំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន (RILGP) ដែលគាំទ្រដល់ការបង្កើនការផ្ទេរ សារពើពន្ធដល់ឃុំនានា។ RGC ក៏ធ្វើការសាកល្បងប្រកបដោយជោគជ័យផងដែរលើគំរោង "សេវាកម្មតែមួយកន្លែង" និង ការិយាល័យអ្នកនាំពាក្យបណ្តឹងថ្នាក់ស្រុក ដើម្បីលើកកំពស់អភិបាលកិច្ច។ ក៏ប៉ុន្តែ ការរីកចំរើនលើការកែលំអសិទ្ធិទទួលបាននូវ ព័ត៌មានមានការយឺតយ៉ាវ។

***១៣. ប៉ូលទី ២ របស់ CAS គាំទ្រដល់ការបង្កើតនិងការអនុវត្តយុទ្ធសាស្ត្រមួយដែលដឹកនាំដោយរដ្ឋាភិបាល និង កម្មវិធីវិនិយោគសំរាប់សំរេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ដែលផ្តោតទៅលើគោលបំណងពីរ គឺ*** (១) គាំទ្រ ដល់ការបង្កើតនិងអនុវត្តយុទ្ធសាស្ត្រមួយដែលដឹកនាំដោយរដ្ឋាភិបាល និងឆ្លើយតបទៅនឹងកម្មវិធីវិនិយោគសំរាប់ការកាត់បន្ថយ ភាពក្រីក្រ និងសំរេចបានគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា និង(២) គាំទ្រដល់សេវាកម្មវិនិយោគ និងវិភាគទាំងឡាយណាដែល ស្ថិតក្រោមវិស័យនិងអនុវិស័យដែលទទួលមូលនិធិចាំបាច់ដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា។ ការរីកចំរើន

លើប៉ូលទី ២ របស់ CAS មានលក្ខណៈរឹងមាំ ដែល ៩៥ ភាគរយ នៃសូចនាករមធ្យមត្រូវបានបញ្ចប់ ឬគន្លងត្រឹមត្រូវ ។ ការរីកចំរើនលើគោលបំណងនីមួយៗនេះត្រូវបានសង្ខេបជូននៅខាងក្រោមបរិយាយលំអិតនៅក្នុងឯកសារភ្ជាប់ ១។

***១៤. ការរីកចំរើនលើការបង្កើតនិងអនុវត្ត NSDP មានលក្ខណៈគួរឱ្យចាប់អារម្មណ៍។*** RGC បានអនុម័ត NSDP នៅក្នុងឆ្នាំ ២០០៦ ដែលជំនួសផែនការមុនៗដែលជំរុញដោយម្ចាស់ជំនួយ ដោយយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិតែមួយគត់ ។ ក្រៅពីការគាំទ្រផ្ទាល់ដល់ស្ថាប័នរបស់រាជរដ្ឋាភិបាល និងដំណើរការនានា ដែលទាក់ទងទៅនឹង NSDP ធនាគារពិភពលោក បានកែលំអមូលដ្ឋាននៃចំណេះដឹងសំរាប់អ្នកបង្កើតគោលនយោបាយ និងភាគីពាក់ព័ន្ធដទៃទៀតជាច្រើន តាមរយៈ *ការវាយតំលៃលើភាពក្រីក្រ* ឆ្នាំ ២០០៦ និង *ការចែករំលែកកំណើនៈសមធម៌ និងរបាយការណ៍អភិវឌ្ឍន៍* ឆ្នាំ ២០០៧។

***១៥. ការរីកចំរើនលើការគាំទ្រផ្នែកវិភាគនិងវិនិយោគទុន ដើម្បីឱ្យសំរេចបាននូវគោលដៅអភិវឌ្ឍន៍ សហសវត្សរ៍កម្ពុជាក្នុងការអភិវឌ្ឍធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធក៏មានលក្ខណៈគួរអោយចាប់អារម្មណ៍ផងដែរ។*** មានការរីកចំរើននៅក្នុងលទ្ធផលនៃការអភិវឌ្ឍធនធានមនុស្សភាគច្រើន រួមមានដូចជា អត្រាស្លាប់របស់កុមារ អត្រាភាព មានជីវជាតិ អត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍ និងអត្រាចុះឈ្មោះចូលរៀន ។ មានការកើនឡើងយ៉ាងខ្លាំងនូវឱកាសទទួលបាន និងប្រើប្រាស់សេវាសុខភាព អប់រំ និងហេដ្ឋារចនាសម្ព័ន្ធ និងការឧបត្ថម្ភផ្នែកសុខភាពនិងអប់រំកាន់តែប្រសើរឡើង ។ ធនាគារពិភពលោក បានគាំទ្រដល់ការរីកចំរើនលើវិស័យសង្គមកិច្ច តាមរយៈការបន្តការគាំទ្រដល់គំរោងគាំទ្រផ្នែកសុខភាព និងគំរោងគាំទ្រផ្នែកអប់រំ និងតាមរយៈការជួយរាជរដ្ឋាភិបាលឱ្យអនុម័តនូវមូលនិធិជំរុញសំរាប់កម្មវិធីអប់រំសំរាប់ទាំងអស់គ្នា គំនិតផ្តួចផ្តើមតាមដានរហ័ស ក៏ដូចជា តាមរយៈការចូលរួមនៅក្នុងក្រុមការងារបច្ចេកទេស (TWG)។

១៦. នៅក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធ រាជរដ្ឋាភិបាលកម្ពុជា បានជួសជុលផ្លូវនៅតាមជនបទ ខេត្ត និងថ្នាក់ជាតិ ហើយកំពុងតែបង្កើតនូវយុទ្ធសាស្រ្តវិស័យលើផ្នែកថាមពល និងទឹកនិងអនាម័យជាដើម ។ ធនាគារពិភពលោក បានចូលរួមចំណែកតាមរយៈគំរោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមួយចំនួន និងបានគាំទ្រដល់ការអភិវឌ្ឍយុទ្ធសាស្រ្តអនុវិស័យ តាមរយៈ AAA មួយចំនួនក៏ដូចជាតាមរយៈការចូលរួមនៅក្នុង TWG ដែរ ។ ការផ្អាករយៈពេល ៨ ខែ នៃ គំរោងវិនិយោគទុនចំនួនពីរ (សូមមើលឯកសារភ្ជាប់ ១) បានធ្វើឱ្យយឺតយ៉ាវដល់ការរីកចំរើនលើការអនុវត្តហេដ្ឋារចនាសម្ព័ន្ធ ក៏ប៉ុន្តែគំរោងទាំងនេះ នៅចុងបញ្ចប់ផ្តល់ផលប្រយោជន៍ដល់ការអភិវឌ្ឍគួរឱ្យកត់សំគាល់ ។ ធនាគារពិភពលោក ក៏បានចាប់ផ្តើមនូវគំនិតផ្តួចផ្តើមថ្នាក់តំបន់ លើផ្នែកពាណិជ្ជកម្មថាមពល និងការគ្រប់គ្រងធនធានទឹកតាមរយៈកម្មវិធីមហាអនុតំបន់មេគង្គរបស់ខ្លួន។

## ខ. ភាពជាដៃគូ និងរបៀបវារៈនៃប្រសិទ្ធិភាពជំនួយ

***១៧. មានការរីកចំរើនគួរឱ្យកត់សំគាល់នៅក្នុងការអនុវត្តសេចក្តីប្រកាសទីក្រុងប៉ារីស និងក្នុងការកែលំអប្រសិទ្ធិភាពជំនួយ ក៏ប៉ុន្តែនៅមានបញ្ហាប្រឈមសំខាន់ៗជាច្រើន។*** ទាំងនៅថ្នាក់ម៉ាក្រូ និងថ្នាក់វិស័យ មានការរីកចំរើនច្រើនលើផ្នែកភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រដ្ឋាភិបាល លើដំណើរការដែលបានបង្ហាញថាមានការផ្លាស់ប្តូរ ពីកិច្ចប្រជុំពិគ្រោះយោបល់ (CG) ទៅវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) ដែលដឹកនាំដោយរដ្ឋាភិបាល និងនៅក្នុងភាពជាអ្នកដឹកនាំរបស់រដ្ឋាភិបាលក្នុងការចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំគណកម្មាធិការសម្របសម្រួលម្ចាស់ជំនួយរបស់រដ្ឋាភិបាល

(GDCC) និង TWGs តាមវិស័យ ។ ចំពោះកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់អំពីគោលនយោបាយវិញមានសង្កត់ភាពកាន់តែខ្លាំងឡើង និងមានការបែងចែកនូវអាទិភាពជាច្រើនជាមួយនឹងដៃគូអភិវឌ្ឍន៍នានា មានការបញ្ជូនសាររួមជាច្រើនទៅឱ្យរដ្ឋាភិបាល ។ ចំពោះផ្នែកតាមវិស័យ ក៏មានការរីកចំរើនមួយចំនួនដែរ គឺមានការទទួលស្គាល់ជាផ្លូវការនូវអភិក្រមគ្របដណ្តប់លើ វិស័យចំនួន ៧ ឬយុទ្ធវិធីផ្នែកលើកម្មវិធី (PBA) ។ ក៏ប៉ុន្តែ ជំនួយរបស់ម្ចាស់ជំនួយដាច់ដោយឡែកនៅតែជាបញ្ហា ជាពិសេសចំពោះក្រសួងសុខាភិបាល និងក្រសួងអប់រំ ។ ឧទាហរណ៍ ផ្នែកសុខាភិបាលមានម្ចាស់ជំនួយចំនួន ២២ កំពុងធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលចំនួនជាង ១០០ អង្គការ ដែលផ្តល់នូវជំនួយអភិវឌ្ឍន៍ផ្លូវការចំនួន ១១០ លាន ដុល្លារក្នុងមួយឆ្នាំតាមរយៈគំរោងចំនួន ១០៩ គំរោង ។ ការប្រើប្រាស់ប្រព័ន្ធជាតិ ក៏នៅតែមានកំរិតទាបនៅឡើយ (ស្ថិតនៅចន្លោះពី ១៣ ទៅ ១៨ ភាគរយ) ដែលឆ្លុះបញ្ចាំងឱ្យឃើញអំពីបញ្ហាប្រឈមនានាដែលនៅសេសសល់ទាក់ទងទៅនឹងការពង្រឹងប្រព័ន្ធនៅក្នុងប្រទេស ។

***១៨. ធនាគារពិភពលោក បានផ្តល់នូវការគាំទ្រយ៉ាងច្រើនដល់រាជរដ្ឋាភិបាលកម្ពុជា លើការសម្របសម្រួលដល់ម្ចាស់ជំនួយ និងដើរតួនាទីឈានមុខគេក្នុងការអភិវឌ្ឍតួនាទីរួមរបស់ម្ចាស់ជំនួយ លើបញ្ហាកំណែទំរង់គោលនយោបាយសំខាន់ៗ ដែលលើកកំពស់ដល់គុណភាពនៃកិច្ចពិភាក្សាស្តីពីគោលនយោបាយរវាងរដ្ឋាភិបាលនិងម្ចាស់ជំនួយ ។*** ក្នុងឋានៈជាសហប្រធានក្នុងដំណើរការនៃកិច្ចប្រជុំពិគ្រោះយោបល់ ហើយឥឡូវនេះ ជាអ្នកដឹកនាំការសម្របសម្រួលឈានមុខដល់ម្ចាស់ជំនួយសំរាប់ CDCF ធនាគារពិភពលោក បានដើរតួនាទីដ៏សំខាន់មួយក្នុងការជួយដល់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំឱ្យរួចរាល់នូវយន្តការនានាសំរាប់កិច្ចពិភាក្សាផ្លាស់ប្តូរយោបល់ទៀងទាត់ ក្នុងចំណោមដៃគូទាំងអស់ ។ នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ CDCF សូចនាករតាមដានរួម (JMIs) ត្រូវបានអនុម័តលើផ្នែកមួយចំនួន ដែលកំណត់នូវការផ្លាស់ប្តូរនានាសំរាប់ធ្វើកំណែទំរង់ក្នុងពេលអនាគត ហើយបន្ទាប់មកត្រូវបានត្រួតពិនិត្យដោយ TWGs និងតាមរយៈកិច្ចប្រជុំ GDCC ប្រចាំត្រីមាស ។

***១៩. ទំនាក់ទំនងជាមួយដៃគូ CAS របស់ក្រុមធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី អង្គការ DFID និងអង្គការក្នុងប្រព័ន្ធ UN នៅតែមានលក្ខណៈរឹងមាំ និងដំណាក់កាលសំខាន់ៗជាច្រើន ដែលបានបង្ហាញជាផ្នែកមួយនៃដំណើរការរួមរបស់ CAS ឥឡូវនេះត្រូវបានអនុម័តកាន់តែទូលំទូលាយ ។*** ធនាគារពិភពលោក បានបន្តសម្របសម្រួលយ៉ាងមានប្រសិទ្ធិភាពជាមួយដៃគូដទៃផ្សេងទៀតដែលពាក់ព័ន្ធនៅក្នុងដំណើរការរួមរបស់ CAS តាមរយៈការប្រជុំពិនិត្យមើលឡើងវិញលើយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រទេសរួមប្រចាំឆ្នាំ និងតាមរយៈការធ្វើទស្សនកិច្ចប្រចាំឆ្នាំ របស់គណៈគ្រប់គ្រងរបស់ធនាគារពិភពលោកទៅកាន់ទីស្នាក់ការកណ្តាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងទីស្នាក់ការកណ្តាលរបស់អង្គការ DFID ។ ធនាគារពិភពលោក ក៏មានភាពជាដៃគូត្រីភាគីស្រដៀងគ្នាមួយ ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី និងប្រទេសជប៉ុនផងដែរ ដែលគាំទ្រតាមរយកិច្ចប្រជុំទៀងទាត់របស់ក្រុមគណៈគ្រប់គ្រង នៅទីក្រុងតូក្យូ ឬទីក្រុងម៉ានីល ។ ដៃគូដទៃទៀត ក៏បានបង្ហាញអំពីបំណងប្រាថ្នារបស់ខ្លួនក្នុងការចូលរួមក្នុងដំណើរការនេះ និងចូលរួមធ្វើឱ្យក្រុមម្ចាស់ជំនួយមានទំហំកាន់តែ ធំឡើងដែលនឹងរៀបចំយុទ្ធសាស្ត្ររួមមួយដើម្បីគាំទ្រដល់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលលើកក្រោយ ។ ជាមួយនឹងការផ្លាស់ប្តូរការយកចិត្តទុកដាក់ពីការសម្របសម្រួលដល់ម្ចាស់ជំនួយនៅថ្នាក់ជាតិ ទៅថ្នាក់វិស័យ ដំណាក់កាលសំខាន់ៗ ជាច្រើន ដែលបានបង្ហាញតាមរយៈ CAS (ដូចជាការអភិវឌ្ឍគោលការណ៍ភាពជាដៃគូ និងការគាំទ្ររួមដល់យុទ្ធសាស្ត្រជាតិផ្នែកលើការវិភាគរួម និងការផ្លាស់ប្តូរទៅរកប្រព័ន្ធត្រួតពិនិត្យនិងរាយការណ៍រួម) កំពុងត្រូវបានចាប់ផ្តើមអនុវត្តកាន់តែច្រើនឡើងនៅថ្នាក់វិស័យដោយក្រុមការងារបច្ចេកទេស ។

***២០. ធនាគារពិភពលោក ក៏បានពង្រឹងនូវភាពជាដៃគូរបស់ខ្លួនផងដែរ ជាមួយភាគីពាក់ព័ន្ធដទៃទៀតតាមរយៈការទំនាក់ទំនងមួយដែលមានលក្ខណៈទូលំទូលាយ និងកម្មវិធីផ្សព្វផ្សាយ។*** ការិយាល័យប្រចាំប្រទេសរបស់ធនាគារពិភពលោក បានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីលើកកំពស់ការយល់ដឹងជាសាធារណៈអំពីបញ្ហាអភិវឌ្ឍន៍សំខាន់ៗ និងតួនាទីរបស់ធនាគារពិភពលោកដែលមាននៅក្នុងការដោះស្រាយបញ្ហាទាំងនេះ តាមរយៈកម្មវិធីផ្សព្វផ្សាយ ដែលមានលក្ខណៈទូលំទូលាយរបស់ខ្លួនដែលបានរួមបញ្ចូលភាគីពាក់ព័ន្ធជាច្រើនទាំងនៅថ្នាក់ជាតិ និងថ្នាក់អនុជាតិ រួមទាំងសមាជិកសភា មន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ និងមន្ត្រីរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ម្ចាស់ជំនួយ សហគមន៍ពាណិជ្ជកម្ម និងសង្គមស៊ីវិល។ ធនាគារពិភពលោក បានផ្ដោតការយកចិត្តទុកដាក់ជាពិសេសលើការអភិវឌ្ឍការយល់ដឹងជាសាធារណៈអំពីបញ្ហាអភិបាលកិច្ចនៅក្នុងប្រទេសកម្ពុជា ក៏ដូចជា ដើម្បីបង្កើននូវការចូលរួមពីប្រជាពលរដ្ឋថ្នាក់ក្រោមផងដែរ។ ធនាគារ ក៏បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងផងដែរ ដើម្បីបង្កើននូវការយល់ដឹងជាសាធារណៈអំពីសមធម៌យេនឌ័រ និងតួនាទីសំខាន់របស់ស្ត្រីនៅក្នុងការអភិវឌ្ឍ។ នៅចន្លោះពីឆ្នាំ២០០៦ ដល់ ២០០៧ ធនាគារពិភពលោក បានរៀបចំនូវព្រឹត្តិការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ នៅក្នុងខេត្តចំនួន ១៤ ក្នុងចំណោមខេត្តទាំង ២៤ របស់កម្ពុជា ដែលបានមានការចូលរួមពីមន្ត្រីរដ្ឋាភិបាលថ្នាក់ខេត្តនិងស្រុក សមាជិកក្រុមប្រឹក្សាឃុំ ប្រធានភូមិ ក្រុមយុវវ័យ អង្គការមិនមែនរដ្ឋាភិបាល និងបណ្ដាញព័ត៌មាន។ ព្រឹត្តិការទាំងនេះ បានជួយជំរុញឱ្យមានការពិភាក្សាផ្លាស់ប្ដូរយោបល់គ្នាអំពីបញ្ហាអភិវឌ្ឍន៍យ៉ាងទូលំទូលាយ។ ធនាគារពិភពលោក ក៏បានបង្កើតនូវវិធីផ្សេងៗជាច្រើនដូចជា កម្មវិធីវិទ្យុ ឬវីដេអូ ដើម្បីលើកកំពស់នូវប្រសិទ្ធិភាពនៃកម្មវិធីទំនាក់ទំនងរបស់ខ្លួន និងផ្សព្វផ្សាយឱ្យដល់ភាគីពាក់ព័ន្ធឱ្យបានច្រើនបន្ថែមទៀត។

## គ. យន្តការនិងការអនុវត្តនៅថ្នាក់គំរោង

***២១. ការរីកចំរើនលើការអនុវត្ត CAS បង្ហាញពីប្រសិទ្ធិភាពនៃការប្រើប្រាស់នូវយន្តការជាច្រើន រួមទាំងកម្មវិធីដ៏រឹងមាំ របស់ AAA និងប្រតិបត្តិការជាច្រើនដែលទាក់ទងទៅនឹងកម្មវិធី ការវិនិយោគតាមវិស័យ និងមូលនិធិមរតកនៃទំនុកចិត្ត។*** រហូតមកដល់ពេលនេះ កិច្ចការរបស់ AAA សរុបចំនួន ២៣ ត្រូវបានបញ្ចប់ ហើយកិច្ចការចំនួន ៦ បន្ថែមទៀតនឹងត្រូវបញ្ចប់នៅចុងឆ្នាំសារពើពន្ធ ២០០៨។ ការរីកចំរើននេះ ប្រៀបធៀបជាមួយនឹងកិច្ចការរបស់ AAA ចំនួន ៣១ ដែលបានកំណត់នៅក្នុង CAS សំរាប់រយៈពេលដូចគ្នា។ ធនាគារពិភពលោក ក៏បានផ្ដល់ផងដែរនូវប្រតិបត្តិការ IDA ចំនួន ៧ ចាប់តាំងពី CAS ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល រួមទាំងគំរោងថ្នាក់តំបន់ចំនួន ១ គឺគំរោងពាណិជ្ជកម្មថាមពល GMS) និងគំរោងការពារ ជំងឺគ្រុនផ្ដាសាយបក្សី និងមនុស្ស។ ប្រតិបត្តិការរបស់ IDA ចំនួនពីរបន្ថែមទៀតគឺ គំរោងបែងចែកដីសង្គមកិច្ច និងដើម្បីការអភិវឌ្ឍសេដ្ឋកិច្ច (LASED) និង RAMP កំពុងត្រូវបានពិភាក្សាតាមរយៈរបាយការណ៍នេះហើយគំរោងផ្នែកសុខាភិបាលមួយ ក៏គ្រោងនឹងអនុម័តនៅក្នុងឆ្នាំសារពើពន្ធ ២០០៨ នេះផងដែរ។ គំរោងទាំង ១០ នេះប្រៀបធៀបជាមួយគំរោងចំនួន ១២ ដែល មានសំរាប់ឆ្នាំសារពើពន្ធ ២០០៦-២០០៨ នៅក្នុង CAS។ IFC បានសន្យាផ្ដល់កម្ចីដល់កម្ពុជាសរុបចំនួន ៣៩,៨ លានដុល្លារ ក្នុង ឆ្នាំ ២០០៨ ចំនួននេះ កើនឡើងពី ២៥,៥ លានដុល្លារ ក្នុងឆ្នាំ ២០០៦។ នៅពេលចាប់ផ្ដើម CAS ដំបូងប្រទេសកម្ពុជាបានទទួលជំនួយឥតសំណង IDA ចំនួន ១០០ ភាគរយ ក៏ប៉ុន្តែ ដោយលទ្ធភាពនៃការសងបំណុលរបស់កម្ពុជាមានការកើនឡើង ទើបបច្ចុប្បន្នមានការកែប្រែក្នុងការបែងចែក IDA ពីជំនួយឥតសំណង ១០០ ភាគរយមកនៅត្រឹម ៥០ ភាគរយជាជំនួយឥតសំណង និង ៥០ ភាគរយជាឥណទានវិញ។ នៅត្រឹមថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៨ ផលប័ត្រនេះ មានឥណទាន IDA ចំនួន ១១ និងជំនួយឥតសំណងសរុបចំនួន ២៦០ លាន ដុល្លារ ព្រមទាំងមូលនិធិទំនុកចិត្ត ដែលប្រតិបត្តិដោយទីភ្នាក់ងារប្រតិបត្តិចំនួន ២០ ដែលមានទឹកប្រាក់សរុបប្រហែល ២៨ លានដុល្លារ។ ដោយសារតែ មានការផ្អាកគំរោង ដូច្នេះ អត្រានៃការដកប្រាក់ បានធ្លាក់ចុះដល់ ១៤ ភាគរយ នៅក្នុងឆ្នាំ

២០០៧ ក៏ប៉ុន្តែ បានកើនឡើងវិញសាជាថ្មីនៅក្នុងឆ្នាំ ២០០៨។ ចំនួនគំរោងជាច្រើនដែលមានបញ្ហា ក៏បានថយចុះផងដែរពី ៥ នៅក្នុងឆ្នាំ ២០០៧ មកនៅ ចំនួន ២ ក្នុងខែ មិនា ឆ្នាំ ២០០៨។

***២២. ក្រោយពីការស៊ើបអង្កេតរបស់ផ្នែកសុក្រិតភាពស្ថាប័ន (INT) និងការរកឃើញអំពើពុករលួយ ការឃុបឃិត និងការបន្លំ រាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក បានបង្កើតវិធានការទប់ស្កាត់និងត្រួតពិនិត្យ មួយចំនួន ដើម្បីកាត់បន្ថយហានិភ័យនៃទំនុកចិត្តចំពោះគំរោងដែលផ្តល់ហិរញ្ញប្បទានដោយធនាគារពិភពលោក*** (សូមមើលប្រអប់លេខ ២ អំពីសាវតានៃបញ្ហាទំនុកចិត្ត)។វិធានការដ៏សំខាន់មួយទៀត គឺការអនុម័តនូវផែនការសកម្មភាពប្រឆាំងអំពើពុករលួយដែលហៅថា ក្របខ័ណ្ឌអភិបាលកិច្ចល្អ (GGFs)។ GGFs រួមមានវិធានការជាច្រើនដើម្បីពង្រឹងនិតិវិធីលទ្ធកម្ម ដំណើរការគ្រប់គ្រងហិរញ្ញវត្ថុ ក្រុមបុគ្គលិក យន្តការបណ្តឹង និងការផ្សព្វផ្សាយ និងការត្រួតពិនិត្យខាងក្នុង។ រាជរដ្ឋាភិបាលកម្ពុជា បានស្ម័គ្រចិត្តអនុម័ត GGFs សំរាប់គំរោងដែលផ្តល់ហិរញ្ញប្បទានដោយធនាគារពិភពលោកទាំងអស់ដែលកំពុងមានសកម្មភាព និងគំរោងសំរាប់ពេលអនាគត។ ទោះបីជា GGFs ត្រូវរៀបចំរួចជាស្រេចអស់រយៈពេលជិតមួយឆ្នាំហើយក៏ដោយ ក៏ការត្រួតពិនិត្យមើលឡើងវិញលើការអនុវត្តថ្មីៗនេះ បង្ហាញថា ក៏រិតនៃការអនុវត្តមានការកើនឡើងក្នុងកំឡុងពេលចាប់ផ្តើមដំបូង។ ទាក់ទងនឹងបញ្ហាលទ្ធកម្មមូលដ្ឋាននៃការគ្រប់គ្រងនិងផ្សព្វផ្សាយហិរញ្ញវត្ថុ ជាទូទៅមានក៏រិតខ្ពស់នៅគ្រប់គំរោងទាំងអស់។ មានការរីកចំរើនគួរឱ្យកត់សំគាល់លើមូលដ្ឋានទាំងនេះ ទាក់ទងទៅនឹងការកើនឡើងនៃតួនាទីរបស់សង្គមស៊ីវិល យន្តការបណ្តឹងផ្លូវការ និងដំណោះស្រាយ និងការបញ្ជាក់ច្បាស់អំពីការដាក់ទណ្ឌកម្មចំពោះអ្នកធ្វើខុស។ សមត្ថភាពស្ថាប័ន និងបច្ចេកទេសចាំបាច់ត្រូវតែបង្កើន ដើម្បីអនុវត្តឱ្យបានពេលលេញនូវវិធានការទាំងនេះ។ ការពិនិត្យមើលឡើងវិញបន្ថែមទៀត នឹងត្រូវធ្វើបន្តទាំងនៅថ្នាក់ផលប័ត្រនិងថ្នាក់គំរោង។

***២៣. ការប្រើប្រាស់ភ្នាក់ងារលទ្ធកម្មឯករាជមួយ (IPA) គឺជាវិធានការដ៏សំខាន់មួយទៀត ដើម្បីទប់ស្កាត់កំហុសឆ្គងលទ្ធកម្មនាពេលអនាគត។*** នៅពេលដែលធនាគារពិភពលោកតំរូវឱ្យ IPA អនុវត្តលទ្ធកម្មលើគំរោងចំនួនតែបីប៉ុណ្ណោះ ដែលត្រូវបានផ្ទាកកន្លងមករាជរដ្ឋាភិបាល បានសំរេចចិត្តតំរូវឱ្យ IPA អនុវត្តលើគំរោងដែលកំពុងមានសកម្មភាព និងគំរោងសំរាប់ពេលអនាគតទាំងអស់ដែលផ្តល់ហិរញ្ញប្បទានដោយធនាគារពិភពលោក។ សកម្មភាពនេះ បង្ហាញអំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធានានូវភាពស្មោះត្រង់របស់ដំណើរការលទ្ធកម្ម និងដើម្បីបំបាត់នូវការរៀបចំដែលមានលក្ខណៈបក្សពួក និងឃុបឃិត។ IPA ឈ្មោះ ក្រោនអេជិន ត្រូវបានជ្រើសរើសចាប់តាំងពីឆ្នាំ ២០០៧។ ថ្មីៗនេះមានការបង្ហាញថា IPA កំពុងតែជំនួសមុខងារលទ្ធកម្មគំរោងកាន់តែពេញលេញនៅក្នុងផលប័ត្រនេះ នៅពេលដែលបញ្ហាអន្តរកាលជាច្រើនកំពុងត្រូវបានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារពិភពលោក[៣]។

***២៤. ធនាគារពិភពលោក ក៏កំពុងផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេសផងដែរដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើការពង្រឹងនូវសមត្ថភាពរបស់ខ្លួន ក្នុងការរកឱ្យឃើញនិងដោះស្រាយរាល់បញ្ហានានាទាក់ទងទៅនឹងការបន្លំ និង***

---

[៣] ដោយសារតែគ្មានលក្ខខណ្ឌកំណត់មុនសំរាប់ IPA ដូច្នេះ IPA នឹងបន្តអនុវត្តនូវលទ្ធកម្មថ្នាក់ជាតិរបស់គំរោងទាំងអស់ដែលផ្តល់ហិរញ្ញប្បទានដោយធនាគារពិភពលោក នៅក្នុងប្រទេសកម្ពុជា លើកលែងតែមានការយល់ព្រមទាំងសងខាងរវាងធនាគារពិភពលោក និងរាជរដ្ឋាភិបាល។ ការប្រតិបត្តិរបស់ក្រោនអេជិន នឹងត្រូវបានពិនិត្យមើលឡើងវិញដោយរាជរដ្ឋាភិបាលនិងធនាគារពិភពលោក នៅពាក់កណ្តាលដំណើរការអនុវត្ត តាមរយៈកិច្ចសន្យាដំបូង ដែលមានរយៈពេលមួយឆ្នាំ ដើម្បីធ្វើការសំរេចឱ្យបន្តដំណើរការក្នុងដំណាក់កាលបន្ទាប់ទៀត រួមទាំងការពន្យាកិច្ចសន្យារបស់ក្រោនអេជិន ឬការជ្រើសរើស IPA ថ្មី។

***អំពើពុករលួយ។*** រាជរដ្ឋាភិបាល បានតែងតាំងក្រសួងទំនាក់ទំនងសភា ព្រឹទ្ធសភា និងអធិការកិច្ចព្រឹទ្ធសភា (MONASRI) ដែលជាទីភ្នាក់ងាររបស់រដ្ឋាភិបាលទទួលបន្ទុកក្នុងការស៊ើបអង្កេត ធ្វើជាប្រធានក្រុមការងារប្រឆាំងនឹងអំពើពុករលួយ (ACWG)។ តួនាទីរបស់ ACWG រួមមាន ការជួយដល់ទីភ្នាក់ងារដែលកំពុងអនុវត្តគំរោងនានា ដើម្បីបង្កើតនូវវិធានការទប់ស្កាត់ និងដើម្បីត្រួតពិនិត្យមើល ការអនុវត្តរបស់ទីភ្នាក់ងារទាំងនេះនៅថ្នាក់គំរោង។ ដោយសារតែចំណេះដឹង និងបទពិសោធន៍របស់បុគ្គលិករបស់ MONASRI បច្ចុប្បន្ននៅមានកំរិត ធនាគារពិភពលោក (ដោយមានការគាំទ្រពី INT) ក៏បានផ្តល់នូវជំនួយបច្ចេកទេសសំរាប់បណ្តុះបណ្តាល បច្ចេកទេសស៊ើបអង្កេត និងកំពុងគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពរបស់ ACWG ក្នុងការបង្កើត និងត្រួតពិនិត្យមើល GGFs។ ក្រៅពីការគាំទ្រនេះ ធនាគារពិភពលោក កំពុងធ្វើការជាមួយរាជរដ្ឋាភិបាល ដើម្បីកំណត់នូវអ្វីដែលអាចធ្វើបានថែមទៀត ដើម្បីឆ្លើយតបទៅនឹងសំណើរបស់រដ្ឋាភិបាល ដើម្បីឱ្យយល់កាន់តែច្បាស់អំពីដំណើរការរបស់ធនាគារពិភពលោក នៅក្នុងផ្នែកស៊ើបអង្កេត និង គោលនយោបាយផ្សព្វផ្សាយ។

## ឃ. មេរៀនដែលបានរៀនសូត្រ

***២៥. ការវាយតំលៃលើជំនួយអភិវឌ្ឍន៍ប្រទេស (CAE) ថ្មីៗចុងក្រោយនេះសំរាប់ប្រទេសកម្ពុជា បានផ្តល់នូវមេរៀនសំខាន់ៗមួយចំនួនសំរាប់ធ្វើការកែលំអយុទ្ធសាស្ត្រជំនួយនាពេលអនាគត។*** ទោះបីជា CAE បានពិនិត្យមើលលើជំនួយសំរាប់កម្ពុជា ពីឆ្នាំ ១៩៩៩ ដល់ ចុងឆ្នាំ ២០០៦ ក៏ដោយ ក៏អនុសាសន៍ជាច្រើនមានទាក់ទងទៅនឹង CAS បច្ចុប្បន្ន ហើយនឹងប្រាប់ឱ្យបន្តកម្មវិធី CAS តទៅទៀត។ គណៈគ្រប់គ្រងបានឯកភាពជាមួយនឹងអនុសាសន៍របស់ CAE ដែលឱ្យធនគារពិភពលោកបន្តការងារដែលមានការពេញចិត្តរបស់ខ្លួននៅក្នុងវិស័យជាច្រើនទៀត រួមទាំងវិស័យអប់រំ សុខាភិបាល ការវិភាគលើភាពក្រីក្រ និង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ CAE បានបង្ហាញអំពីការរីកចំរើន ដែលមានកំរិតលើផ្នែកអភិបាលកិច្ច នៅក្នុងកំឡុងពេលធ្វើការវាយតំលៃ និងបានជំរុញឱ្យធនាគារពិភពលោកបន្តផ្តោតការយកចិត្តទុកដាក់ថែមទៀតលើបញ្ហាអភិបាលកិច្ច នៅក្នុងជំនួយ របស់ខ្លួន ហើយបន្តផ្តោតការយកចិត្តទុកដាក់ឱ្យកាន់តែខ្លាំងថែមទៀតលើការត្រួតពិនិត្យមើលលើទំនុកចិត្តនៅក្នុងផលប័ត្រនេះ។ ដូចដែលរបាយការណ៍នេះ បានពិពណ៌នារួចមកហើយអនុសាសន៍ទាំងនេះត្រូវបានដាក់បញ្ចូលទៅក្នុង CAS បច្ចុប្បន្ននេះរួចទៅហើយ ហើយនឹងត្រូវបានថែរក្សានៅក្នុងដំណាក់កាលស្នើសុំបន្តទៀត។

***២៦. ទោះបីជាក្រុមធនាគារពិភពលោក មិនមែនជាម្ចាស់ជំនួយឈានមុខគេនៅក្នុងវិស័យកសិកម្មក៏ដោយ ក៏ CAE ចាត់ទុកវាជាវិស័យមួយដែលធនាគារពិភពលោក កំពុងតែធ្វើការវិនិយោគនាពេលបច្ចុប្បន្នតាមទស្សនៈរបស់រាជរដ្ឋាភិបាល។*** ជាការពិតនាពេលបច្ចុប្បន្នធនាគារពិភពលោកមិនបានវិនិយោគទៅលើធាតុចូលផ្នែកកសិកម្មដែលមានលក្ខណៈបុរាណ ឬធារាសាស្ត្រខ្នាតធំនៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏ធនាគារពិភពលោកបានផ្តល់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសយ៉ាងច្រើននៅក្នុងអនុវិស័យជាច្រើន ដែលមានសារសំខាន់ចំពោះការអភិវឌ្ឍកសិកម្ម និងជនបទ។ ធនាគារពិភពលោកបានពាក់ព័ន្ធក្នុងការគាំទ្រដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និងរដ្ឋបាល ការពង្រីកផ្លូវនៅជនបទ និងការផ្គត់ផ្គង់អគ្គិសនី និងវិមជ្ឈការ និងវិសហមជ្ឈកាដែលរួមចំណែកក្នុងការអភិវឌ្ឍកសិកម្ម។ ធនាគារពិភពលោក ក៏បានចាប់ផ្តើមធ្វើការងារវិភាគផងដែរលើការរួមចំណែករបស់កសិកម្មចំពោះកំណើន និងឧបសគ្គនានាចំពោះការអភិវឌ្ឍរបស់ខ្លួន។ IFC បានចូលរួមនៅក្នុងការងារផ្តល់យោបល់ជាមួយធនាគារនានា និងស្ថាប័នមីក្រូហិរញ្ញវត្ថុជាច្រើន ដើម្បីផ្តល់ហិរញ្ញប្បទាន ដល់ផ្នែកកសិកម្ម និងជួយ សំរបសំរួលដល់ការបង្កើនប្រភេទនៃផលិតផល។ ដំណើរឆ្ពោះទៅមុខ ក្រុមធនាគារពិភពលោក នឹងបន្ត ធ្វើការងារដែលបានកំណត់ ទិសដៅនេះ លើឧបសគ្គនានាចំពោះការបង្កើនប្រភេទកសិកម្ម និងការបង្កើនផលិតភាព។

***២៧. ក្រុមធនាគារពិភពលោកបានរៀនសូត្រពីបទពិសោធន៍នៃចរិកលក្ខណៈនៃការរៀបចំ CAS រួមគ្នា ហើយមេរៀននេះ នឹងអាចរៀបចំ និងអនុវត្តយុទ្ធសាស្ត្រជំនួយសំរាប់អនាគតនៅប្រទេសកម្ពុជា និងនៅប្រទេសដទៃទៀត ។*** ពិតណាស់ការរៀបចំយុទ្ធសាស្ត្ររួមគ្នាត្រូវការពេលវេលាច្រើន និងចំណាយថវិកាច្រើន ប៉ុន្តែវាក៏បានផ្តល់លទ្ធផលដ៏មានប្រយោជន៍ច្រើនដែរ ។ ការសម្របសម្រួលធានាឱ្យមានការនិយាយដូចគ្នាចំពោះកម្មវិធីគោលនយោបាយ និងកម្មវិធីជំនួយ ។ ការផ្តោតការយកចិត្តទុកដាក់ និងជំរើសដែលជ្រើសយកដាក់បញ្ចូលទៅក្នុង CAS រួមគ្នាអនុញ្ញាតឱ្យដៃគូអភិវឌ្ឍន៍នានាប្តេជ្ញាចិត្តសំរាប់ការចូលរួមរយៈពេលវែងនៅក្នុងប្រទេស ។ វាក៏អាចបង្កលទ្ធភាពឱ្យដៃគូនានាប្រើប្រាស់អភិក្រមរួមលើគ្របវិស័យឱ្យកាន់តែច្រើនថែមទៀតសំរាប់ជំនួយរបស់ពួកគេ ដែលអាចកាត់

**ប្រអប់ ២ : អំពើពុករលួយនៅក្នុងផលប័ត្រ**

ជាផ្នែកមួយនៃការរៀបចំ CAS សំរាប់កម្ពុជា តំបន់អាស៊ីបូព៌ា បានចាប់ផ្តើមអនុវត្តការពិនិត្យមើលឡើងវិញលើការប្រើប្រាស់ថវិការការឱ្យចំគោលដៅ (FR) រួមគ្នាជាមួយរដ្ឋាភិបាល និងដោយមានជំនួយពី INT ចន្លោះពីខែកក្កដា ឆ្នាំ ២០០៤ ដល់ ខែកញ្ញា ឆ្នាំ ២០០៥ ។ នៅពេលនោះ FR គឺគ្រាន់តែជាការងារទីបីរបស់ធនាគារពិភពលោកប៉ុណ្ណោះ ហើយជាការងារតែមួយគត់ដែលសហការជាមួយរដ្ឋាភិបាល ។ បន្ទាប់ពី FR ការស៊ើបអង្កេតឯករាជ្យរបស់ INT បានរកឃើញនូវភស្តុតាងអំពីអំពើពុករលួយការឃុបឃិត និងការក្លែងបន្លំ លើកិច្ចសន្យាចំនួន ៤៩ ក្នុងគំរោងចំនួន ៧ (គំរោង ៤ កំពុងដំណើរការ និង ៣ ត្រូវបានបិទ) ។ លទ្ធផលនៃការស៊ើបអង្កេតនេះត្រូវបានបញ្ជូនទៅ កាន់ការិយាល័យតំបន់ នៅក្នុងខែ ឧសភា ឆ្នាំ ២០០៦ ។

នៅក្នុងខែ មិថុនា ឆ្នាំ ២០០៦ ធនាគារពិភពលោក បានប្រកាសអំពីកំហុសលទ្ធកម្មនៅក្នុងកិច្ចសន្យាចំនួន ៤២ និងបានប្រកាសអំពីភាពគ្មានសិទ្ធិចំណាយលើកិច្ចសន្យាចំនួនមួយលើគំរោងសរុបចំនួន ៥ (គំរោងចំនួន ២ ត្រូវបានបិទ និង ៣ កំពុងមានសកម្ម ភាព) ដែលមានទឹកប្រាក់សរុប ១២,២ លានដុល្លា ។ ថវិការបស់ធនាគារពិភពលោកចំនួន ៨,២៥ លានដុល្លារ ត្រូវបានប្រើប្រាស់សំរាប់ផ្តល់ហិរញ្ញប្បទានដល់កិច្ចសន្យាទាំងនេះ ។ ក្រៅពីនេះ ធនាគារពិភពលោក បានផ្អាកការបើកប្រាក់លើគំរោងដែលកំពុងមានសកម្មភាពចំនួន ៣ ហើយធនាគារពិភពលោកជាមួយរដ្ឋាភិបាលបានបង្កើតឡើងនូវផែនការសកម្មភាព (ក្នុងខែកក្កដា ឆ្នាំ ២០០៦) សំរាប់ រដ្ឋាភិបាលអនុវត្តដើម្បីលប់ចោលនូវការផ្អាកទាំងនេះ ។ ការផ្អាកទាំងនេះ រួមទាំងការជំទាស់របស់រាជរដ្ឋាភិបាលលើដំណើរការស៊ើបអង្កេត (និងយុទ្ធវិធីក្នុងការចែករំលែកព័ត៌មានអំពីភស្តុតាងនៃអំពីពុករលួយ) បានឈានទៅដល់ដំណាក់កាលមួយដែលធ្វើឱ្យមានឧបសគ្គធ្ងន់ធ្ងរដល់កិច្ចពិភាក្សាដែលមានប្រសិទ្ធិភាព ។ ក៏ប៉ុន្តែ នៅពាក់កណ្តាលដើមខែកុម្ភៈ ឆ្នាំ ២០០៧ ធនាគារពិភពលោក បានលប់ចោលការផ្អាកលើគំរោងទាំងបី បន្ទាប់ពីមានការព្រមព្រៀងគ្នាជាមួយរដ្ឋាភិបាលអំពីវិធីសាស្ត្រកែលំអអភិបាលកិច្ចនៅក្នុងការអនុវត្តគំរោងទាំងនេះ ហើយសកម្មភាពដំបូងដែលបានយល់ព្រម គឺការអនុវត្ត និងការអនុម័តក្របខ័ណ្ឌអភិបាលកិច្ចល្អ (GGFs) ផងដែរ ។

ធនាគារពិភពលោក និងរដ្ឋាភិបាលបានឈានដល់កិច្ចព្រមព្រៀងមួយ កាលពីខែមិថុនា ឆ្នាំ ២០០៧ លើ (១) ការដកយកមូលនិធិវិញជាបន្ទាន់ចំនួន ២,៨៩ លានដុល្លារ (៣៥ ភាគរយ នៃ ៨,២៥ លានដុល្លារ របស់មូលនិធិដែលបើកឱ្យដោយ (IDA) របស់មូលនិធិដែលបើកឱ្យដោយ IDA (ប្រាក់ដែលនៅសល់ត្រូវប្រគល់អោយវិញតាមកាលបរិច្ឆេតធម្មតា) (២) ការអនុម័ត GGFs សំរាប់គំរោងដែលកំពុងបន្តចំនួន ៥ ផ្សេងទៀត តាមរយៈការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងច្បាប់ និង (៣) ការបង្កើតនូវក្រុមការងារប្រឆាំងនឹងអំពើពុករលួយ (ACWG) មួយដើម្បីកំណត់ជំរុញ និងអនុវត្តនូវវិធានការប្រឆាំងនឹងអំពើពុករលួយក្នុងភាពជាដៃគូដ៏ជិតស្និទ្ធិជាមួយធនាគារពិភពលោក ។ រដ្ឋាភិបាល បានប្រគល់មូលនិធិវិញតាមចំនួនដែលបានព្រមព្រៀង បានអនុម័តនូវ GGFs សំរាប់គំរោងចំនួន ៤ ជិតបានបញ្ចប់ GGFs សំរាប់គំរោងដែលនៅសល់ បានបង្កើតនូវ លក្ខខណ្ឌតំរូវការសំរាប់ ACWG និងបានតែងតាំងសមាជិកដែលមានសក្តនុពលជាច្រើន ។

បន្ថយបន្ទុករដ្ឋាភិបាលក្នុងការអនុវត្តគំរោងជាច្រើននៅក្នុងវិស័យដូចគ្នា ។ ស្របពេលនឹងមានការរឹតបន្តឹងរបស់គំរោងដែលគាំទ្រដោយធនាគារពិភពលោកចំពោះស្តង់ដារនៃការប្រើប្រាស់ថវិកាឱ្យចំគោលដៅនៅក្នុងកម្ពុជា និងការឈានឆ្ពោះទៅរកអភិក្រមរួមលើគ្របវិស័យចំពោះកម្មវិធីផ្គត់ផ្គង់ បានបង្កឱ្យមានការលំបាកដល់ការអនុវត្តនានាផងដែរ។ ការងារទាំងពីរនេះ ត្រូវការពេលវេលា និងអាចមានលំបាកក្នុងប្រទេសដែលមានបុគ្គលិកចំនួនតិច ។ លើសពីនេះទៅទៀត ទាមទារឱ្យមានជំនាញក្នុងការតាមដានការប្រើប្រាស់ថវិកាឱ្យចំគោលដៅ ហើយការសម្របសម្រួលលើគ្របវិស័យ (មិនចាំបាច់ត្រូវការជំនាញដូចគ្នាទេ) ហើយវាក៏ត្រូវការបុគ្គលិកនៅក្នុងប្រទេស និងត្រូវការធនធានផងដែរ ។

## ៣. ការពង្រឹង និងការបន្តសុពលភាពកម្មវិធីរបស់ CAS

***២៨. ការពិគ្រោះយោបល់នាពេលថ្មីៗនេះជាមួយនឹងអ្នកពាក់ព័ន្ធនានា បានស្នើឡើងថា វិធីសាស្ត្រ និងគោលដៅរបស់ CAS នាពេលបច្ចុប្បន្ននៅតែមានលក្ខណះសមស្រប។*** អ្នកពាក់ព័ន្ធបានស្នើថា CAS ដែលធ្វើរួមគ្នាជាមួយដៃគូនានានេះ គួរបន្តការចែកការងារទទួលបន្ទុកដែលមាននាពេលបច្ចុប្បន្នឱ្យនៅដដែល ហើយបានស្នើសុំឱ្យធនាគារពិភពលោកបន្តជ្រើសរើសការងាររបស់ខ្លួនឱ្យបានស៊ីជំរៅ ជាជាងការចូលរួមចំណែកទូលំទូលាយខ្លាំងពេក ដោយសារថាខ្លួនជាអ្នកផ្តល់ថវិកាតិចតួចសំរាប់ប្រទេសកម្ពុជា (មានប្រមាណតែ ១០ ភាគរយនៃជំនួយមកកាន់ប្រទេសកម្ពុជាទាំងមូល) ការពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធ ក៏បានបង្ហាញការគាំទ្រយ៉ាងពេញទំហឹងដោយសុំឱ្យមានការតឹមជំនួយនានារបស់ម្ចាស់ជំនួយឱ្យត្រូវទៅតាម NSDP ថ្មី ដែលគ្រោងនឹង រៀបចំនៅឆ្នាំ ២០១១។ បន្ថែមពីលើក CAS ដែលមានការចូលរួមពីម្ចាស់ជំនួយនានាពីមុនមកនោះ ពេលនេះមានម្ចាស់ជំនួយជាច្រើនទៀត បានសំដែងចំណាប់អារម្មណ៍របស់គេចង់រួបរួមគ្នាជាមួយនឹង CAS របស់ធនាគារពិភពលោក ប្រសិនបើវានឹងត្រូវបានរៀបចំដោយតឹមទៅតាម NSDP។ ជាចុងក្រោយការយឺតយ៉ាវដែលកើតចេញពីការប្រើប្រាស់ថវិកាឱ្យចំគោលដៅមានបញ្ហានោះ បានធ្វើឱ្យរបៀបវារៈមួយចំនួនដែលមាននៅក្នុងកម្មវិធីរបស់ CAS មិនបានអនុវត្តឱ្យចប់ចុងចប់ដើម។

***២៩. ឆ្លើយតបទៅនឹងការចាប់អារម្មណ៍ទាំងនេះ ធនាគារពិភពលោកបានស្នើសុំបន្តសុពលភាព CAS រហូតដល់រយៈរបស់ IDA ខាងមុខ ។ ការបន្តសុពលភាពទាំងនេះនឹងអាចអនុញ្ញាតឱ្យធនាគារពិភពលោកតាក់តែង CAS ពេលក្រោយឱ្យស្របទៅ នឹង NSDP ថ្មីរបស់រាជរដ្ឋាភិបាល ។ កម្មវិធីដែលផ្តោតការយកចិត្តទុកដាក់របស់ក្រុមធនាគារពិភពលោក នឹងនៅតែបន្តទៅលើអភិបាលកិច្ចដដែល ប៉ុន្តែបានដាក់បញ្ចូលនូវបទពិសោធន៍នានាដែលបានរៀនសូត្រនាពេលអនុវត្ត CAS កន្លងមកនិងធានាថា វិធីសាស្ត្រនៅក្នុងស្រុកស្របទៅនឹងអាទិភាពជាសកលដែលរៀបចំដោយ ធនាគារពិភពលោកនៅក្នុងកម្មវិធីអភិបាលកិច្ច និងយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយ (C-GAC) ។*** កម្មវិធីដែលបានស្នើឡើងសំរាប់ពន្យាសុពលភាព CAS គឺមានពណ៌នានៅក្នុងតារាងទី ១ និងមាននៅក្នុងបច្ចុប្បន្នភាព និងម៉ាទ្រិចទៅក្នុងឯកសារយោងទី ៣ ជាភាសាអង់គ្លេស ។ កម្មវិធីបានផ្អែកទៅលើ មធ្យោបាយជាច្រើនសំរាប់សម្របសម្រួលឱ្យការអនុវត្តCAS នេះប្រកបទៅដោយប្រសិទ្ធិភាព។គំរោងកាត់បន្ថយភាពក្រីក្រ និងប្រតិបត្តិការដើម្បីកំណើន នឹងបន្តវដ្តរបស់ខ្លួនមួយឆ្នាំម្តងៗ ជាមួយនឹងការគាំទ្រហិរញ្ញវត្ថុពី សហដៃគូអភិវឌ្ឍន៍នានា ។ ប្រតិបត្តិការវិនិយោគ នឹងជួយបំពេញបន្ថែមបន្តទៅទៀតតាមរយៈការគាំទ្របច្ចេកទេសពីធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត ។ កម្មវិធីទាំងអស់នឹងកំណត់ដោយការសិក្សាស្រាវជ្រាវវិភាគដែលមានទំនាក់ទំនង ហើយនឹងអំពីបញ្ហាចំពោះសុវត្ថិភាពនៃការប្រើប្រាស់ថវិកាឱ្យចំគោលដៅ ។ ចំនួនទឹកប្រាក់ដែលគាំទ្រដោយ IDA សំរាប់ប្រតិបត្តិការនីមួយៗ ដែលកំណត់ថាជា ចំនួនសរុបនៃធនធានរបស់ IDA សំរាប់ប្រទេសកម្ពុជា គឺអាស្រ័យទៅលើការអនុវត្ត IDA១៥ ដោយផ្អែកលើប្រព័ន្ធបែងចែកថវិកា ។ ការបន្តឱ្យមានពិន្ទុល្អសំរាប់ CPIA នឹងអាចជួយបង្កើនការផ្តល់ធនធានទាំងនេះ ។ ការបន្តការកាត់បន្ថយបំណុល ដែលមានហានិភ័យខ្ពស់សំរាប់ប្រទេស ក៏នឹងអាចឈាន

ចេញពីការទទួលបានថវិកាពាក់កណ្ដាលជាជំនួយឥតសំណង និងពាក់កណ្ដាលទៀតជាឥណទាន ទៅជាប្រាក់ឥណទាន ១០០ ភាគរយតែម្ដង ។ ប្រសិនបើសេនារីយោនេះអាចលេចចេញជារូបរាងមែន ធនាគារពិភពលោក នឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាលដើម្បីធានាឱ្យការផ្លាស់ប្ដូរនេះឱ្យមានភាពប្រសើរ និងមានការរំពឹងទុកបានល្អ ។

***៣០. ចំពោះការងារអភិបាលកិច្ចទាំងមូល ធនាគារពិភពលោកនឹងបន្តលើវិធីសាស្ត្រពីររបស់ខ្លួននៃការផ្តល់ការគាំទ្រ ដើម្បីលើកកំពស់ប្រព័ន្ធអភិបាលកិច្ច ទន្ទឹមនឹងពេលរក្សាការត្រួតពិនិត្យ និងការមើលនៅក្នុងការរៀបចំគំរោង និងការចាត់ចែងការចុះមកត្រួតពិនិត្យគំរោង ដើម្បីកាត់បន្ថយហានិភ័យលើការប្រើប្រាស់ថវិកាឱ្យចំគោលដៅនៅក្នុងផលប័ត្ររបស់ធនាគារពិភពលោក ។*** បន្ថែមពីវិធានការដែលបានរៀបរាប់ពីដើមនៅក្នុងរបាយការណ៍នេះ ធនាគារពិភពលោកក៏បានបោះជំហានមួយជំហានទៀតចំពោះការពង្រឹងសមត្ថភាពផ្ទាល់របស់ខ្លួន និងការកែសំរួលយុទ្ធសាស្ត្រចុះត្រួតពិនិត្យរបស់ខ្លួនសំរាប់ដោះស្រាយការប្រឈមនានាដែលកើតមានឡើងពីការពង្រឹង និងការទាមទារឱ្យមានការពិនិត្យមើលឱ្យប្រសើរលើការប្រើប្រាស់ថវិកាឱ្យចំគោលដៅ។ អាចឱ្យការងារនេះដំណើរការទៅបាន គឺបន្ថែមថវិកាសំរាប់ចុះត្រួតពិនិត្យគំរោង ក៏ដូចជាការជ្រើសរើសទៅតាមប្រធានបទ និងផលប័ត្រដែលត្រូវចុះត្រួតពិនិត្យ ។ វាក៏នឹងចូលរួមផ្តល់ការគាំទ្រកំរិតខ្ពស់ចំពោះការគ្រប់គ្រងលទ្ធកម្ម និងហិរញ្ញវត្ថុ ពីការិយាល័យនៅក្នុងប្រទេស និងការរីកចំរើនឥតឈប់ឈរចំពោះវិមជ្ឈការលើការងារទាំងនេះ និងការកសាងសមត្ថភាព ។ ធនាគារពិភពលោក នឹងពង្រឹងលទ្ធកម្មលើការពិនិត្យមុន និងការពិនិត្យលើតំណាក់កាលអន្តរកាលហិរញ្ញវត្ថុ ការអនុវត្តនៃការតាមដានលើក្របខ័ណ្ឌអភិបាលកិច្ចល្អ ការកំណត់ការផ្គត់ផ្គង់ទៅដល់ទីកន្លែង និងការពិនិត្យលើគុណភាពដើម្បីតាមដានហានិភ័យលើការប្រើប្រាស់ថវិកាឱ្យចំគោលដៅក្នុងអំឡុងពេលដែលខ្លួនចុះត្រួតពិនិត្យ ។ កម្ពុជាក៏ជាប្រទេសមួយដែលសាកល្បងអនុវត្តកម្មវិធី C-GAC ផងដែរ ។ ការពង្រឹងសមត្ថភាពបន្ថែមទៀតត្រូវការកសាងជំនាញឱ្យបានទូលំទូលាយ ដែលទាមទារសំរាប់គាំទ្រគំនិតផ្តួចផ្តើមអភិបាលកិច្ចនេះ ហើយកំរិតថ្នាក់ខ្ពស់ចំពោះការពិនិត្យមើលនឹងត្រូវបានផ្តល់ជូនដោយផ្នែកអភិបាលកិច្ចជាន់ខ្ពស់ប្រចាំតំបន់ ដែលនឹងត្រូវបង្កើតដើម្បីគាំទ្រការិយាល័យ ទៅតាមប្រទេសនីមួយៗ ។

***៣១. ធនាគារពិភពលោកនឹងបន្តគាំទ្ររាជរដ្ឋាភិបាល និងធ្វើការជាមួយដៃគូអភិវឌ្ឍន៍នានា សំរាប់ការអនុវត្តសេចក្តីប្រកាសទីក្រុងប៉ារីស ក៏ដូចជាការធ្វើការជាមួយអ្នកពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងវិស័យឯកជន និងសង្គមស៊ីវិល ។*** ចំណុចពិសេសនោះ គឺ ការពង្រឹងក្រុមការងារបច្ចេកទេស និងការឈានឆ្ពោះទៅរកអភិក្រមរួមទូទាំងវិស័យ និងវិធីសាស្ត្រធ្វើការរួមគ្នា ក៏ដូចជា ការទទួលស្គាល់ផលលំបាកខាងសមត្ថភាព និងការធានាជាចាំបាច់ចំពោះសុវត្ថិភាពការប្រើប្រាស់ថវិកាឱ្យចំគោលដៅ ។ ធនាគារពិភពលោកក៏នឹងទទួលយកការដឹកនាំម្ចាស់ជំនួយនានាស្តីការរៀបចំយុទ្ធសាស្ត្ររួមគ្នានៅក្នុងការគាំទ្រចំពោះ NSDP និងការពង្រឹងបន្ថែមចំពោះទំនាក់ទំនង និងកម្មវិធីផ្សព្វផ្សាយ ។

***៣២. ធ្វើការដើម្បីលើកកំពស់ការអភិវឌ្ឍវិស័យឯកជន (គោលដៅទី ១) ក្នុងអំឡុងពេលសុពលភាព CAS នេះ នឹងបន្តកសាង លើមេរៀនបីដែលបានរៀនសូត្រពី CAS ។*** ទីមួយ គឺការខិតខំបន្ថែមទៀតចំពោះសកម្មភាពសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ផ្សេងៗទៀតឱ្យបានស៊ីជំរៅ តាមរយៈអភិក្រមរួមទូទាំងវិស័យចំពោះពាណិជ្ជកម្ម ហើយប្រើប្រាស់សកម្មភាពរួមគ្នានៅក្នុងក្រុមធនាគារពិភពលោក ។ ទី២ ចំពោះការងារបំពេញបន្ថែមដើម្បីពន្លឿនផ្នែកតំរូវការឱ្យមានអភិបាលកិច្ចល្អ ធនាគារពិភពលោកនឹងពង្រីកកិច្ចខិតខំប្រឹងប្រែងដើម្បីជំរុញវិស័យឯកជន ឱ្យកំណត់វិស័យដែលត្រូវកំណែទំរង់ និងការតំរូវឱ្យរដ្ឋាភិបាលមានការទទួលខុសត្រូវ ។ ទី៣ ក្រុមធនាគារពិភពលោកនឹងកំណត់ការផ្តោតការយកចិត្តទុកដាក់របស់ខ្លួនចំពោះវិស័យ កសិពាណិជ្ជកម្ម ដែលវាជាប្រភពធនធានដ៏សំខាន់សំរាប់កំណើននាពេលអនាគតដោយសារតែប្រទេសនេះពឹងផ្អែកទៅលើវិស័យកសិកម្ម និងនៅពេលដែលចំណីអាហារឡើងថ្លៃ ។

ដើម្បីគាំទ្ររបៀបវារៈដែលបានពង្រីកនេះ ក្រុមធនាគារពិភពលោក កំពុងតែចាប់ផ្តើមធ្វើការសិក្សាវាយតំលៃទៅលើបរិយាកាសវិនិយោគទុន ការសិក្សាអំពីប្រភពនៃកំណើន ការងារដែលផ្តល់ជាយោបល់ទាក់ទិនទៅនឹងការងារធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ សំរាប់ផ្តល់ហិរញ្ញវត្ថុដល់ចង្វាក់តំលៃកសិកម្ម និងសម្របសម្រួល លើភាពចំរុះនៃផលិតកម្ម ដែលជាឯកសាគោលនយោបាយមួយ ចំពោះផលប៉ះពាល់ដែលបណ្តាលមកពីការកើនឡើងតំលៃម្ហូបអាហារ និងប្រេង និងបន្តការពង្រីកការងារដាក់ពិន្ទុ លើបរិយាកាសពាណិជ្ជកម្មនៅតាមថ្នាក់ខេត្តឱ្យបានទូទាំងប្រទេស ។ IFC/MPDF បានដាក់បំពេញបន្ថែមការគាំទ្ររបស់ខ្លួនជាលើកទី៣ ហើយ IFC មានផែនការដើម្បីពង្រីកទំហំវិនិយោគទុនរបស់ខ្លួននៅប្រទេសកម្ពុជា ។ នៅក្នុងវិស័យពិតប្រាកដសំរាប់ការវិនិយោគនេះ នឹងផ្តោតទៅលើការគាំទ្រការអភិវឌ្ឍ និងការអនុវត្តគំរោងពាណិជ្ជកម្ម ដូចជាវិស័យទូរគមនាគមន៍ ភ្លើងអគ្គិសនី ផ្លូវដែក ផ្លូវថ្នល់ និងវិស័យផ្សេងៗទៀត ដែលមិនមែនរដ្ឋ ចំណែកឯវិស័យហិរញ្ញវត្ថុវិញ គឺផ្តោតទៅលើការផ្តល់កម្ចីដល់មីក្រូហិរញ្ញវត្ថុ និងសហគ្រាសខ្នាតតូច និងមធ្យម (SME) ។ មូលនិធិមរតកសំរាប់ការអភិវឌ្ឍជំនួញមួយ នឹងត្រូវបង្កើតឡើងនៅឆ្នាំ ២០០៨ នេះ ដើម្បីគាំទ្រអភិក្រមរួមទូទាំងវិស័យសំរាប់ពាណិជ្ជកម្ម ហើយជំនួយបច្ចេកទេសសំរាប់ការអភិវឌ្ឍវិស័យឯកជនថ្មីមួយដែលប្រតិបត្តិដោយ IDA គឺគ្រោងនឹងធ្វើឡើងនៅឆ្នាំ ២០១១ និងមានការគាំទ្របន្ថែមផងដែរពី PRGOs ។

***៣៣. ការគាំទ្ររបស់ធនាគារពិភពលោកចំពោះការលើកកំពស់ការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិដើម្បីជាផលប្រយោជន៍ សំរាប់សហគមន៍ជនបទ (គោលដៅទី ២) នឹងបន្តទៅមុខទៀតលើភាពរីកចំរើនដែលកើតមាននារយៈពេល ៥ ឆ្នាំកន្លងមក និងដាក់បញ្ចូលផងដែរចំពោះការប្រឈមនានាដែលកើតមានឡើង។*** គ្របដណ្តប់ការគ្រប់គ្រងធនធានធម្មជាតិនឹងបន្តណែនាំឱ្យធនាគារពិភពលោកចូលរួមនៅក្នុងវិស័យនេះ ដោយបញ្ជាក់បន្ថែមទៅលើវិធីសាស្រ្តបង្កើនតម្លាភាព វិមជ្ឈការ និងភាពជាដៃគូនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។ ក្នុងអំឡុងពេលដែល CAS នៅជាធរមាន មូលដ្ឋានច្បាប់សំរាប់គ្រប់គ្រងដីធ្លីសាធារណៈ និងការធានាសុវត្ថិភាពកម្មសិទ្ធិដីធ្លីមានលក្ខណៈប្រសើរច្រើន ប៉ុន្តែនៅតែមានការប្រឈមជាច្រើនទៀតក្នុងការជួយរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ មិនមែនរដ្ឋ ដើម្បីចាប់យកបទពិសោធន៍ជាក់ស្តែងសំរាប់ការអនុវត្តនីយតកម្មនេះ ។ ក្នុងអំឡុងពេលអនុវត្ត CAS ទៅខាងមុខនេះ នឹងសង្កត់ធ្ងន់ទៅលើលទ្ធផលដែលកើតមាននៅថ្នាក់ក្រោម និងការកំណត់នូវឱកាស ដើម្បីពង្រីកទំហំវិធីសាស្រ្ត អនុវត្តជាក់ស្តែងនៅក្នុងវិស័យដីសម្បទានសង្គមកិច្ច ការផ្តល់ចំណេះដឹងស្តីអំពីច្បាប់ដីធ្លី និងការដោះស្រាយទំនាស់ ការគ្រប់គ្រងដីរដ្ឋ ការកំណត់ព្រំប្រទល់ព្រៃ ការគ្រប់គ្រងព្រៃសហគមន៍ និងតំបន់ការពារ ការអភិវឌ្ឍកសិកម្មសំរាប់កសិករខ្នាតតូច និងសិទ្ធិកាន់កាប់ដីធ្លីរបស់ជនជាតិភាគតិច ។ ស្របពេលជាមួយគ្នានេះដែរ បញ្ហាបន្ថែមដែលមិនបានគ្រោងទុកក្នុងការអនុវត្ត CAS កន្លងមកបានកើតឡើងជាបញ្ហាសំខាន់ដល់គោលដៅវិស័យទាំងមូលដោយសារតែការកើនឡើងយ៉ាងលឿនចំពោះតំលៃដី ដែលនាំឱ្យមានការកើនឡើងទីផ្សារដីធ្លីមិនផ្លូវការ ។ សំរាប់ពេលនេះ និងពេលខាងមុខ ធនាគារពិភពលោក នឹងធ្វើការសិក្សាស្រាវជ្រាវវាយតំលៃចំពោះផលលាភទាំងផ្លូវការ និងមិនផ្លូវការ ដែលនាំទៅរកទីផ្សារដីធ្លីពិតប្រាកដ ដោយរួមទាំងការបង់ពន្ធនិងកំរៃ និងដើម្បីកំណត់ផលប៉ះពាល់លើក្រុម ដែលងាយរងគ្រោះដោយទាំងអ្នកក្រ ក្រុមអ្នកក្រដែលរស់នៅទីប្រជុំជន និងសហគមន៍ជនជាតិ ។ ស្របទៅនឹង CAS នេះដែរ មូលនិធិអភិវឌ្ឍន៍សង្គមរបស់ប្រទេសជប៉ុន (JSDF) និងមូលនិធិមរតកដែលគាំទ្រជា ច្រើនទៀតនឹងបន្តធ្វើការជាមួយរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិលនានាដើម្បីកំណត់នូវវិធីសាស្រ្តដែលអាចអនុវត្តបាន ដើម្បីដោះស្រាយសម្ពាធដែលកើតមានឡើងរវាង កំណើនយ៉ាងលឿន ការអភិវឌ្ឍសេដ្ឋកិច្ច និងការការពារសុវត្ថិភាពដល់ការរស់នៅ របស់ប្រជាជនក្រីក្រនៅទីប្រជុំជន និងសហគមន៍ ជនជាតិភាពតិច ។ ការងារនេះ នឹងត្រូវដាក់បញ្ចូលទៅក្នុងការតាក់តែងអំពីតួនាទី របស់ធនាគារពិភពលោក តាមរយៈគំរោងគ្រប់គ្រងដីធ្លី និងរដ្ឋបាលលើកទី២ ដែលគ្រោងនឹងធ្វើឡើងនៅឆ្នាំ ២០១០ ហើយការគាំទ្រពីម្ចាស់ជំនួយជាច្រើន ចំពោះវិធីសាស្រ្តអាស្រ័យលើកម្មវិធី ចំពោះដីធ្លីត្រូវបានបង្កើតនាពេលបច្ចុប្បន្ននេះ ដោយមានការគាំទ្រពីម្ចាស់ជំនួយជាសលក សំរាប់ការអភិវឌ្ឍជនបទ ក៏ដូចជាការគាំទ្របន្ថែមទៀតតាមរយៈ PRGOs ។

***៣៤. ក្នុងអំឡុងពេលអនុវត្ត CAS ដែលបានពន្យានេះ កម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គោលដៅទី ៣) មានគោលបំណងដោះស្រាយបញ្ហាប្រឈមនៃអភិបាលកិច្ចគន្លឹះ២មួយចំនួន ។*** ទីមួយ កម្មវិធីនេះនឹងធ្វើការយ៉ាងណាដើម្បីលើកកំពស់ប្រសិទ្ធិភាព និងតម្លាភាពក្នុងការប្រមូលធនធាន និងការចូលរួមនៅក្នុងដំណើរការគំនិតផ្តួចផ្តើមឱ្យមានតម្លាភាពនៅក្នុងវិស័យឧស្សាហកម្មនិស្សារណកម្ម (EITI) ដោយអាស្រ័យទៅលើក្របខ័ណ្ឌសំរាប់ការរំពឹងទុកនៃការបង្កើនចំណូលពីវិស័យឧស្សាហកម្មនិស្សារណកម្មនេះ ។ ទី២ កម្មវិធីនឹងពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ និងពង្រឹងសមត្ថភាពធនធានមនុស្ស ដើម្បីគាំទ្រដំណើរ វិមជ្ឈការ និងវិសហមជ្ឈការដែលកំពុងតែដំណើរការ ដើម្បីលើកកំពស់ការផ្គត់ផ្គង់សេវា និងបង្កើនការទទួលខុសត្រូវរបស់រដ្ឋាភិបាលចំពោះតំរូវការរបស់ប្រជាពលរដ្ឋ ។ ទី៣ កម្មវិធីនឹងគាំទ្រកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយបញ្ហានៅក្នុងលទ្ធកម្ម ការប្រើប្រាស់ថវិកាឱ្យចំគោលដៅ និងសមត្ថភាព ដូចនេះអន្តរាគមន៍ជាក់ស្តែងសំរាប់គំរោងអាចនឹងជួយដល់ប្រព័ន្ធរដ្ឋាភិបាល និងធ្វើសុខដុមបណីយកម្មលើការចាត់ចែងជំនួយរបស់ម្ចាស់ជំនួយ ។ ធនាគារពិភពលោក ក៏នឹងគាំទ្រចំពោះការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ធនធានមនុស្ស និងភ្នាក់ងារសវនករ ដែលនឹងទទួលខុសត្រូវចំពោះការពិនិត្យមើលនៃប្រព័ន្ធគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ ។ ចុងក្រោយ ធ្វើឱ្យប្រសើរចំពោះគំលាតសារពើពន្ធ ។ ដំណើរការរីកចំរើនលើ MBPI និងការបង្កើតនៃទំនាក់ទំនងមួយជាមួយនឹងក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល (CAR) បានបង្កើតនូវឱកាសថ្មីដើម្បីគាំទ្រកំណែទំរង់សេវាស៊ីវិល ។ នាឆ្នាំ ២០០៩ ខាងមុខនេះ ធនាគារពិភពលោកនឹងគាំទ្រ CAR ដើម្បីពិនិត្យឡើងវិញជាពិសេសចំពោះស្ថានភាពបច្ចុប្បន្ននៃការបង្កើតផែនការសកម្មភាព ដ៏គួឱ្យជឿទុកចិត្តបានសំរាប់ដោះស្រាយកំណែទំរង់សេវាស៊ីវិល និងប្រាក់បៀវត្ស ។ ការងារវិភាគនេះ នឹងកំណត់សំរាប់កម្មវិធីដែលបានលើកឡើង ដោយរួមទាំងរបាយការណ៍ការផ្តល់យោបល់ពីខាងក្រៅជាប្រចាំឆ្នាំ ការវាយតំលៃកំណែទំរង់រដ្ឋបាល ដែលនឹងធ្វើឡើងនៅឆ្នាំ ២០០៩ ហើយនៅឆ្នាំ ២០១០ នឹងធ្វើបច្ចុប្បន្នភាពឡើងវិញ ចំពោះរបាយការណ៍ពិនិត្យឡើងវិញលើការវាយតំលៃការប្រើប្រាស់ថវិកាឱ្យចំគោលដៅ និងការចំណាយសាធារណៈ (IFAPER) ។ ការផ្តល់ជំនួយសំរាប់កម្មវិធីនេះ គឺនៅមានរហូតដល់បំណាច់ឆ្នាំ ២០១០សំរាប់ PFMRP MDTF [៦] ហើយជំនួយឥតសំណងរបស់ IDA ដល់ PFMAP ទោះបីជាជំនួយបន្ថែមនេះទាមទារឱ្យមានការប្រើប្រាស់ IPA នៅពេលដែល IPA កំពុងតែដំណើរការ ហើយជំនួយនេះ ក៏នឹងមានការងារសំរាប់ PAR ដែរ ។ កំណែទំរង់ PFM លើកទីពីរនឹងគ្រោងធ្វើឡើងនៅឆ្នាំ ២០១០ ហើយការគាំទ្របន្ថែម នឹងត្រូវបានផ្តល់តាមរយៈសេរីរបស់PRGOs ។

***៣៥. ធនាគារពិភពលោកបានឈានជើងមួយជំហានទៀត ចំពោះការគាំទ្រវិមជ្ឈការ និងជំរុញភាពជាដៃគូជាមួយប្រជាពលរដ្ឋ សំរាប់អភិបាលកិច្ចល្អ (គោលដៅទី ៤) នាពេលអនុវត្ត CAS បន្តទៀត ។*** ធនាគារពិភពលោក ក៏ដូចជាដៃគូអភិវឌ្ឍន៍ដែលនឹងផ្តល់ការគាំទ្របច្ចេកទេសសំរាប់ការអនុវត្តច្បាប់អង្គការថ្មីស្តីអំពីវិមជ្ឈការ និងវិសហមជ្ឈការ និងមានការវិនិយោគបន្ថែម និងការគាំទ្របច្ចេកទេសតាមរយៈគំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋានថ្មី ។ ធនាគារពិភពលោកក៏នឹងបង្កើនការគាំទ្រសំរាប់ផ្នែកទាមទារដើម្បីឱ្យមានអភិបាលកិច្ចល្អដោយចូលរួមពីអ្នកពាក់ព័ន្ធជាច្រើនសំរាប់កំណែទំរង់ ឧទាហរណ៍ ប្រជាពលរដ្ឋ យុវជន សារព័ត៌មាន សមាជិកសភា វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល ម្ចាស់ជំនួយ និងអាជ្ញាធរសវនករ ។ ដោយសារថា កម្មវិធីពង្រឹងផ្នែកទាមទារតំរូវការត្រូវការកសាងរយៈពេលវែង ធនាគារពិភពលោកបានកំពុងតែចាប់ផ្តើមអនុវត្តសកម្មភាពពង្រឹងការទាមទារមួយដែលមានថវិកាជំនួយឥតសំណងមួយពីមូលនិធិមរតកសំរាប់ប្រទេសដែលមានចំណូលទាប និងមានភាពផុយស្រួយ (LICUS) សំរាប់កម្មវិធីកសាងសមត្ថភាពសង្គមស៊ីវិលលើការទទួលខុសត្រូវសង្គម និងប្រតិបត្តិការកម្ចីថ្មីចំនួនពីរៈ គំរោងទាមទារឱ្យមានអភិបាលកិច្ចល្អ (សូមមើលប្រអប់ទី៣) ដើម្បីពង្រឹងស្ថាប័នរដ្ឋ និងស្ថាប័នមិនមែនរដ្ឋចំពោះការទទួលខុសត្រូវ និងគំរោងផ្តល់អំណាចឱ្យប្រជាជនក្រីក្រនៅខេត្តសៀមរាប

---

[៦] MDTF គឺមានដៃគូអភិវឌ្ឍន៍ចំនួន១៣ដែលគាំទ្រ PFMRP SWAP ជាមួយនឹងជំនួយដាក់ចូលគ្នារវាងដៃគូអភិវឌ្ឍន៍ចំនួន ៤ តាមរយៈ MDTF មាន AusAID DFID EC និង SIDA

(អាចអនុម័តនៅឆ្នាំសារពើពន្ធ ២០១០) ដើម្បីលើកកំពស់ក្រុមប្រជាជនក្រីក្រ (អង្គការកសិករ ក្រុមមីក្រូហិរញ្ញវត្ថុ សមាគមជួយខ្លួនឯង ។ល។) ដោយផ្សារភ្ជាប់ពួកគាត់ទៅនឹងវិស័យទេសចរណ៍ និងប្រភពនៃកំណើនផ្សេងៗទៀត ។

***៣៦. ធនាគារពិភពលោកនឹងបន្តគាំទ្រពង្រឹងស្ថាប័ននានាឱ្យឆ្លើយតបចំពោះការអនុវត្ត និងការតាមដានលើ NSDP (គោលដៅទី ៥) ។*** ចាប់តាំងពីឆ្នាំ ២០០៩ ការសង្កត់ធ្ងន់នឹងសំដៅទៅលើការបង្កើនការគាំទ្រចំពោះការរៀបចំ NSDP ថ្មី (ឆ្នាំ ២០១១ - ២០១៥) ។ ដោយធ្វើការជាមួយនឹងម្ចាស់ជំនួយនានា និងតួអង្គនៅក្នុងប្រទេស ធនាគារពិភពលោកនឹងចូលរួមចំណែកក្នុងការពិគ្រោះយោបល់គោលនយោបាយ និងផ្តល់ការគាំទ្រហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសក្នុងការគាំទ្រៈ វិធីសាស្ត្រដោយមានការចូលរួមឱ្យបានច្រើនថែមទៀត ដើម្បីវាយតំលៃដំណើរការ និងកំណត់បញ្ហាគោលនយោបាយថ្មី ការវិភាគលំអិតបន្ថែមទៀតលើគន្លងសេដ្ឋកិច្ច និងសង្គម ការអនុវត្តរបស់រដ្ឋាភិបាល និងការរឹតបន្តឹងទំនាក់ទំនងរវាងគោលនយោបាយអាទិភាពនៅក្នុង NSDP និងស្ថាប័នសំរាប់ផ្តល់ធនធានដោយផ្ទាល់ចំពោះកម្មវិធីអាទិភាពនេះ ។ មធ្យោបាយគន្លឹះនានាដើម្បីគាំទ្រការងារនេះនឹងមូលនិធិ មរតកចំនួនពីរសំរាប់ការសិក្សាស្រាវជ្រាវវិភាគផ្តល់យោបល់នឹងផ្តល់ការគាំទ្រដោយផ្ទាល់ទៅក្រសួងផែនការ ។ ធនាគារពិភពលោកនឹងបន្តគាំទ្រការងារយេនឌ័រ ជាពិសេសនៅក្នុងការងារបញ្ជ្រាបយេនឌ័រនៅក្នុងវដ្ត NSDP ដោយផ្តោតទៅលើការតាមដាន និងការវាយតំលៃ ។

***៣៧. ការងាររបស់ធនាគារពិភពលោកសំរាប់ការអភិវឌ្ឍធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធ (គោលដៅទី ៦) ចំពោះ CAS នេះ នឹងផ្តោតបន្ថែមទៀតទៅលើអភិក្រមរួមទូទាំងវិស័យ និងធានាថា សុវត្ថិភាពចាំបាច់ចំពោះការប្រើប្រាស់ថវិកាឱ្យចំគោលដៅត្រូវបានអនុវត្ត ។*** តាមការរំពឹងទុក មិនមានអ្វីផ្លាស់ប្តូរជាដុំកំភួននៅក្នុងការងាររបស់ធនាគារពិភពលោកទេ នៅក្នុងវិស័យសុខាភិបាល និងវិស័យដឹកជញ្ជូន ។ ចំពោះវិស័យអប់រំវិញ ធនាគារពិភពលោកប្រហែលជាពង្រីកការចូលរួមរបស់ខ្លួន ចំពោះកម្មវិធីអប់រំដំបូង និងការអប់រំថ្នាក់ឧត្តម ។ នៅក្នុងវិស័យថាមពលវិញ ធនាគារពិភពលោកនឹងបន្តផ្តោតទៅលើអគ្គិសនីជនបទ និងក៏ផ្តោតទៅលើការបង្កើនការចូលរួមរបស់ខ្លួនចំពោះការអភិវឌ្ឍថាមពលដែលអាចកើតឡើងវិញបាន ។ ចំណែកឯនៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជនវិញ មិនអាចបន្តការចូលរួមបានទេ ដោយសារតែមានភាពតានតឹងនៃទំនាក់ទំនងជាមួយក្រសួងនេះ ចាប់តាំងពីមានការស៊ើបអង្កេតរបស់ INT លើគំរោងដែលគាំទ្រដោយធនាគារពិភពលោក ។ នៅក្នុងវិស័យទាំងពីរ គឺវិស័យសង្គម និងហេដ្ឋារចនាសម្ព័ន្ធ ធនាគារពិភពលោកនឹងបន្តការគាំទ្រដោយផ្អែកទៅលើមធ្យោបាយចំរុះ ដោយរួមទាំងសកម្មភាព AAA អភិក្រមរួមទូទាំងវិស័យ ក៏ដូចជាប្រតិបត្តិការវិនិយោគនានាដែលមានពីមុនមក ។

***៣៨. ម៉ាទ្រិចលទ្ធផលដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារយោងទី៣ជាភាសាអង់គ្លេស) និងរៀបចំឡើងសំរាប់ការតាមដាន និងការវាយតំលៃលើសកម្មភាព CAS ដែលបានបន្តនេះ ។*** ម៉ាទ្រិចនេះតាក់តែងឡើងដោយប្រើប្រាស់ប្រព័ន្ធដ៏ល្អមួយនៃការសម្របសម្រួលដែលចាប់ផ្តើមនៅថ្នាក់ក្រុមការងារបច្ចេកទេស ដែលរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ពិភាក្សាពីគោលដៅជាក់លាក់នៅក្នុងវិស័យនីមួយៗដើម្បីឱ្យឆ្លើយតបទៅនឹង NSDP ។ ការតាមដានតាមវិស័យទាំងនេះ នឹងទាញចេញពីការជួបប្រជុំគ្នារវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលធ្វើឡើងក្នុងរយៈពេលបីខែម្តងនៅឯជំនួប GDCC និងរយៈពេលមួយឆ្នាំម្តង នៅឯជុំនួប CDCF នៅទីនោះ រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ព្រមព្រៀងគ្នាលើសូចនាករតាមដានរួម ដែលវានឹងតាមដានតាមរយៈ ដំណើរការទៅមុខរបស់ TWG/GDCC ។ ការតាមដានទាំងនេះ ត្រូវបានបំពេញបន្ថែមដោយរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ (APR) ស្តីអំពីការអនុវត្ត NSDP ។ ការកសាងសមត្ថភាពនៃវិទ្យាស្ថានជាតិស្ថិតិតាមរយៈការអនុវត្តផែនការមេស្ថិតិ និងវិទ្យាស្ថានតាមដាននិងវាយតំលៃ គឺមានសារៈសំខាន់ណាស់ដើម្បីលើកកំពស់គុណភាពព័ត៌មាន និងផលប៉ះពាល់របស់វាលើការធ្វើគោលនយោបាយ ។

**ប្រអប់ទី៣: គំរោងការទាមទារឱ្យមានអភិបាលកិច្ចល្អ (DFGG)**

គំរោង **DFGG** គឺរៀបចំឡើងដើម្បីពង្រឹងសមត្ថភាពពលរដ្ឋកម្ពុជាដើម្បីទាមទារឱ្យមានអភិបាលកិច្ចល្អក្នុងការជ្រើសរើស វិស័យគោលនយោបាយសាធារណៈដោយពង្រឹងការសន្យារបស់ស្ថាប័នរដ្ឋ និងស្ថាប័នមិនមែនរដ្ឋដែលកំពុងធ្វើការឆ្ពោះទៅរក (១) ការបង្កើនការទទួលបានរបស់សាធារណៈជនចំពោះព័តិមានដែលត្រឹមត្រូវជាប់ទាក់ទង និងទាន់ពេលវេលា ។ (២) លើកកំពស់ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងភ្នាក់ងាររដ្ឋាភិបាល ។ (៣) សម្របសម្រួលឱ្យមានការឆ្លើយតបជាគន្លឹះពីភ្នាក់ងាររដ្ឋាភិបាល ហើយ (៤) ការតាមដាននូវការអនុវត្តរបស់រដ្ឋាភិបាល ។

គំរោងរំពឹងថានឹងមានផ្នែកសំខាន់ៗបី ។ សំរាប់ផ្នែកទី ១ គឺគាំទ្រស្ថាប័នរដ្ឋ ហើយរដ្ឋាភិបាលកម្ពុជាបានជ្រើសរើសកម្មវិធី ៤ ដែលកំពុងដំណើរការឱ្យពង្រីកបន្ថែមទៀតនៅក្រោមគំរោងនេះ ។ កម្មវិធីទាំងនោះរួមមាន កម្មវិធីរបស់វិទ្យុជាតិ សកម្មភាពផ្សព្វផ្សាយច្បាប់ និងដំណោះស្រាយបណ្តឹងដែលនឹងអនុវត្តដោយក្រសួងទំនាក់ទំនងសភា និងព្រឹទ្ធសភា និង អធិការកិច្ច ការិយាល័យច្រកចេញចូលតែមួយ ដែលកម្មវិធីនេះបានសាកល្បងរួចហើយដោយមានការជួយឧបត្ថមពី សហគមន៍អឺរ៉ុបនៅក្នុងខេត្តចំនួនពីរ ដែលរៀបចំឡើងដោយក្រសួងមហាផ្ទៃ និងកម្មវិធីមួយទៀតគឺដោះស្រាយជំលោះឱ្យកម្មករដែលកម្មវិធីនេះអនុវត្តដោយក្រុមប្រឹក្សាអជ្ញាកណ្តាលនៅក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ស្ថាប័នរដ្ឋទាំងនេះត្រូវបានជ្រើសរើស ដោយសារតែការងារដែលកំពុងអនុវត្តទទួលបានជោគជ័យ និងមានការប្តេជ្ញាចិត្ត ពីថ្នាក់ដឹកនាំចំពោះការគាំទ្រគំរោង DFGG នេះ ហើយមានទំនាក់ទំនងដោយផ្ទាល់ទៅនឹង CAS របស់ធនាគារពិភពលោកសំរាប់ប្រទេសកម្ពុជា ។

បន្ថែមពីលើការរៀបចំដោយស្ថាប័នរដ្ឋ គំរោងនេះនឹងមានបង្អួចមួយទៀត ដើម្បីគាំទ្រអង្គការសង្គមស៊ីវិល និងស្ថាប័នមិនមែនរដ្ឋ ។ វានឹងមានយន្តការប្រកួតប្រជែងមួយ ឬ ពីរ ដើម្បីផ្តល់មូលនិធិដល់ស្ថាប័នមិនមែនរដ្ឋដែលវានឹងអាស្រ័យ ទៅលើការរៀបចំស្នើគំរោងដែលធ្វើការងារដោយផ្ទាល់ ឬនៅជុំវិញប្រធានបទដែលអនុវត្តដោយស្ថាប័នរដ្ឋខាងលើ ។

ផ្នែកទី៣ នឹងគាំទ្រការសម្របសម្រួលលើគំរោងទាំងមូល និងរៀនសូត្រ ដើម្បីសំយោគកំលាំងនានារវាងផ្នែកខុសៗគ្នា និងដាក់បញ្ចូលគ្នាសំរាប់ផលប្រយោជន៍ជាវិជ្ជមានចំពោះអភិបាលកិច្ច ។ ផ្នែកនេះនឹងបង្ហាញពីករណីដែលមានប្រសិទ្ធិភាពចំពោះស្ថាប័នដែលគាំទ្រគំរោងនេះ ដើម្បីបង្កើតជាពន្លឺមួយសំរាប់ស្ថាប័នរដ្ឋ និងមិនមែនរដ្ឋដទៃទៀតក្នុងការទទួលយកការអនុវត្តអភិបាលកិច្ចឱ្យបានប្រសើរ ។

***៣៩. ដើម្បីផ្តត់ផ្គង់ឱ្យបានប្រសើរលើកម្មវិធីផ្សេងៗនៅក្នុងពេលអនុវត្ត CAS ហើយធនាគារពិភពលោកនឹងលើកកំពស់បន្ថែមទៀតចំពោះសមត្ថភាពការិយាល័យរបស់ខ្លួននៅទីក្រុងភ្នំពេញ ។*** នារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះកំណើនបុគ្គលិកបានកើនឡើងយ៉ាងលឿន ដែលមានបុគ្គលិកចំនួន ៤៥ នាក់ទាំងបរទេស និងបុគ្គលិកជាជនជាតិខ្មែរ ។ នៅពេលខាងមុខនឹងមានការកើនឡើងបុគ្គលិកមួយចំនួនតូចទៀត ។ សំខាន់លើសពីនេះទៅទៀត គឺការពង្រីកវិមជ្ឈការការងារគ្រប់គ្រង ដែលទទួលខុសត្រូវដោយការិយាល័យនៅក្នុងប្រទេសដោយស្របទៅ នឹងវិធីសាស្ត្រវិមជ្ឈការ ដែលបានកំណត់ នៅក្នុងយុទ្ធសាស្ត្រតំបន់អាស៊ីបូព៌ា ហើយបុគ្គលិកនឹងពង្រីកបទពិសោធន៍របស់គេ និងការទទួលបានការអប់រំបន្ថែម ។ ចំណុចសង្កត់ធ្ងន់មួយ ទៀត គឺការជំរុញកិច្ចសហប្រតិបត្តិការរវាងបុគ្គលិករបស់ធនាគារពិភពលោក និង IFC នៅក្នុងការអនុវត្ត CAS របស់ក្រុមធនាគារពិភពលោក ។

## ៤. ការគ្រប់គ្រងហានិភ័យ

***៤០. CAS បានកំណត់នូវហានិភ័យមួយចំនួនដែលប្រឈមទៅនឹងគោលដៅអភិវឌ្ឍន៍របស់រដ្ឋាភិបាល និងការអនុវត្តកម្មវិធីរបស់ក្រុមធនាគារពិភពលោក ។*** ទាំងនេះដោយរួមទាំងចរិកលក្ខណៈដែលងាយផុយស្រួយនៃការប្រកួតប្រជែង ជាអន្តរជាតិរបស់ ប្រទេសកម្ពុជា ការប្រឈមចំពោះការអភិវឌ្ឍ និងការអនុវត្តកំណែទំរង់អភិបាលកិច្ច និងហានិភ័យចំពោះការសម្របសម្រួល

ម្ចាស់ជំនួយ ដែលមិនមានលក្ខណៈប្រសើរ ដោយរួមទាំងការលំបាកកសាងទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិល ។ ការពង្រីកការងារនេះត្រូវបានធ្វើឡើងក្រកបដោយប្រសិទ្ធិភាពនៅក្នុងអំឡុងពេលបីឆ្នាំនៃអាយុកាលរបស់CAS ប៉ុន្តែ វានៅមានបញ្ហាខ្លះៗដែរ ។

***៤១. ការរក្សាការប្រកួតប្រជែង និងនិរន្តរភាពកំណើនដែលកើនយ៉ាងឆាប់រហ័សគឺមានសារៈសំខាន់ណាស់ដើម្បីបង្កើតឱ្យមានការងារធ្វើ ដែលកំលាំងពេញសំរាប់ការងារគឺមានប្រមាណ ២៥០,០០០ ក្នុងមួយឆ្នាំៗ (គឺចំនួនអ្នកដែលឈានជើងទៅក្នុងទីផ្សារការងារ) ដើម្បីកាត់បន្ថយភាពក្រីក្រ និងធ្វើឱ្យមាននិរន្តរលទ្ធផលដែលទទួលបាន និងស្ថេរភាពនយោបាយ ។*** ប្រទេសកម្ពុជាបានបន្តកំណើនយ៉ាងលឿននារយៈពេលបីឆ្នាំចុងក្រោយនេះ ប៉ុន្តែការរក្សាកំណើននេះឱ្យមានល្បឿនបែបនេះគឺជាការលំបាកដោយសារថា កំណើនទាំងនោះបានមកពីវិស័យតែមួយចំនួនតូចប៉ុណ្ណោះ ។ មានហានិភ័យចំពោះម៉ាក្រូសេដ្ឋកិច្ចមួយចំនួនធំដែលបានលើកឡើងនៅក្នុងយុទ្ធសាស្ត្រតំបន់ ដោយរួមទាំងការកើនឡើងលើអតិផលរណា តំលៃចំណីអាហារឡើងខ្ពស់នៅលើពិភពលោក តំលៃថាមពល និងតំលៃរបស់របរប្រើប្រាស់នានា និងការរំពឹងទុកនៃសេដ្ឋកិច្ចពិភពលោកមិននឹងន់ ក៏ជាបញ្ហាបន្ថែមផងដែរ ។ រាជ រដ្ឋាភិបាលកម្ពុជាក៏កំពុងតែខិតខំដើម្បីកាត់បន្ថយតំលៃថាមពល តាមរយៈការអភិវឌ្ឍវារីអគ្គិសនី និងថាមពលដែលអាចកកើត ឡើងវិញបានការគ្រប់គ្រងតំរូវការ កាត់បន្ថយប្រព័ន្ធដែលបាត់បង់ប្រសិទ្ធិភាពខ្ពស់ចំពោះការប្រើប្រាស់ម៉ាស៊ីនភ្លើង ក៏ដូចជាការរៀបចំការរុករក និងការផលិតប្រេង និងឧស្ម័ននៅតាមសមុទ្រ ។ វិធានការទាំងនេះ ធ្វើឡើងសំរាប់រយៈពេលមធ្យម និងរយៈពេលវែង ហើយបានរំពឹងថាតំលៃប្រេងដែលថ្លៃខ្ពស់នៅលើពិភពលោក គឺបានប៉ះពាល់យ៉ាងច្រើនមកលើសេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ ។

***៤២. មានការទទួលស្គាល់ដោយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាថា ការរក្សាការផ្តោតទៅកំណែទំរង់អភិបាលកិច្ច គឺមានសារៈសំខាន់ណាស់សំរាប់ការអភិវឌ្ឍប្រកបដោយប្រសិទ្ធិភាព ។*** ជាងបីឆ្នាំកន្លងមកនេះ គឺមានការប្រសើរយ៉ាងខ្លាំងនៅក្នុងការងារអភិបាលកិច្ច ប៉ុន្តែនៅផ្នែកខ្លះត្រូវបានធ្លាក់ចុះទៅវិញ ។ កំណែទំរង់អភិបាលកិច្ច គឺជាដំណើរដ៏វែងឆ្ងាយ និងមានភាពសាំញ៉ាំ ដែលទាមទារឱ្យមានកំណែទំរង់ច្បាស់លាស់ និងមានអត្ថន័យជ្រាវជ្រៅនៅក្នុងស្ថាប័ន ក្នុងការឯកភាពគ្នា និងមានភាពជឿជាក់ និងភាពជាម្ចាស់ការ ។ ដើម្បីឱ្យមានប្រសិទ្ធិភាព សកម្មភាពនានាសំដៅលើអភិបាលកិច្ចត្រូវតែជំរុញឱ្យបានលឿនក្នុងភាពជាម្ចាស់របស់ប្រទេស ។ ជាចុងក្រោយធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៍ពីខាងក្រៅនឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាលនៅវិស័យនានាដែលរដ្ឋាភិបាលបង្ហាញពីការប្តេជ្ញាចិត្តចំពោះកំណែទំរង់ ដូចជាការអភិវឌ្ឍវិស័យឯកជន ការគ្រប់គ្រងធនធានធម្មជាតិ ការគ្រប់គ្រងធនធាន និងវិមជ្ឈការ និងការទទួលខុសត្រូវសង្គម ។

***៤៣. ការគ្រប់គ្រងដោយប្រសិទ្ធិភាពចំពោះលំហូរចូលនៃព្រទ្យធនដែលបានមកពីប្រេង ឧស្ម័ន និងរ៉ែ វានឹងអាចជាចំណុចមួយដែលត្រូវយកចិត្តទុកដាក់សំរាប់របៀបវារៈអភិបាលកិច្ចដ៏ទូលំទូលាយ ។*** ទោះបីជាមិនមានភាពច្បាស់លាស់ចំពោះចំណូលដែលកម្ពុជា នឹងទទួលបានពីប្រេង ពីឧស្ម័ន និងពីរ៉ែក្តី[៥] គឺជារឿងគួឱ្យចាប់អារម្មណ៍ និងអាចមើលឃើញសំរាប់ពាណិជ្ជកម្ម ហើយបទពិសោធន៍នៅក្នុងប្រទេសដែលកំពុងអភិវឌ្ឍន៍នានា បានបង្ហាញថាការគ្រប់គ្រងធនធានអាចមានភាពភ្លាំងភ្លាត់ទោះបីជារដ្ឋាភិបាលនោះមានជំនាញក៏ដោយ ។ ការសិក្សាស្រាវជ្រាវបានបង្ហាញថា ទ្រព្យធននេះនឹងអាចបំផ្លាញអភិបាលកិច្ច ហើយអាចប្រើប្រាស់ខុស

[៥] លក្ខខណ្ឌភូមិសាស្ត្របង្ហាញថាកម្ពុជាប្រហែលជានឹងមានធនធានរ៉ែដែក រ៉ែមាស ម៉ង់ហ្គាណេស រ៉ែប្រាក់ រ៉ែបុកស៊ីត សំណរ និង ស័ង្កសី

និងអំពើពុករលួយ ដែលវានឹងបង្កឱ្យប្រតិបត្តិសេដ្ឋកិច្ចរយៈពេលវែងមានភាពទន់ខ្សោយ ។ ទោះជាយ៉ាងណាក៏ដោយមានប្រទេសជាឧទាហរណ៍មួយចំនួនដែលប្រើប្រាស់ធនធានធម្មជាតិដ៏សំបូរបែបរបស់គេជាប្រយោជន៍សំរាប់កំណើនសេដ្ឋកិច្ច បានបង្ហាញថាការដាក់បណ្ដាសាប្រេងមិនកើតមានទេ ។ ធនាគារពិភពលោកនឹងបន្តគាំទ្របំណងប្រាថ្នាដ៏ធំធេងរបស់រដ្ឋាភិបាលកម្ពុជាតាមរយៈកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសគាំទ្រគោលដៅរបស់រដ្ឋាភិបាលកម្ពុជាដើម្បី (១) ប្រមូលចំណូលឱ្យបានច្រើនពីឧស្សាហកម្មទាំងនេះហើយ (២) ធានាឱ្យមានការចំណាយពីចំណូលទាំងនេះនៅក្នុងផែនការជាអាទិភាពនៅក្នុង NSDP ។ ទោះបីជាធនាគារពិភពលោកមិនចូលរួមដោយផ្ទាល់ជាមួយនឹងវិស័យរ៉ែនៅក្នុងតំណាកកាលនេះក្ដី ការសិក្សាស្រាវជ្រាវ គឺត្រូវបានប្រកាស "ធនធានរ៉ែជាប្រភពមួយនៃកំណើន" ដែលជាផ្នែកមួយនៃការវិភាគជាទូទៅមួយនៃកំណើននៅកម្ពុជា ។ ដូចដែលបានជជែកគ្នានៅក្នុង PRGO II ធនាគារពិភពលោកក៏កំពុងតែគាំទ្ររដ្ឋាភិបាលដើម្បីពិនិត្យឡើងវិញនៃចំណុចប្រសើរ និងមិនប្រសើនៃការឯកភាពចំពោះ EITI ដែលទាមទារឱ្យមានការអះអាង និងការផ្សព្វផ្សាយចំពោះការបង់ថវិកាជូនរដ្ឋពីក្រុមហ៊ុនប្រេងនានា ហើយធនធានពីប្រេងដែលរដ្ឋាភិបាលទទួលបាននោះត្រូវគ្រប់គ្រងឱ្យបានប្រសើរ និងមានប្រយោជន៍ដោយចាប់ផ្ដើមពីចំណុចមួយដែលនឹងពង្រឹងតម្លាភាព និងលើកកំពស់អភិបាលកិច្ច ដែលការងារទាំងនេះគឺត្រូវមានការចូលរួមពីអ្នកពាក់ព័ន្ធជាច្រើន ក្នុងនោះក៏មានអង្គការសង្គមស៊ីវិលផងដែរ ។ ការឯកភាពចំពោះ EITI ត្រូវបានពិនិត្យឡើងវិញ ដែលជាសញ្ញាដ៏ប្រសើរ និងជាមធ្យោបាយដើម្បីធានាថា ប្រសិនបើធនធានដែលប្រមូលបានពីប្រេង ពីឧស្ម័ន ឬបានពីរ៉ែត្រូវចាត់ចែងដោយមធ្យោបាយដ៏ប្រសើរនោះ ផលប្រយោជន៍នឹងជះឥទ្ធិពលជាវិជ្ជមានទៅដល់សេដ្ឋកិច្ច និងអភិបាលកិច្ច ជាជាងការបង្កឱ្យមានការដាក់បណ្ដាសាពីប្រេង ។ តែទោះបីជាមានសញ្ញាប្រកបដោយការចូលរួមក្ដី ដំណើរការ EITI គឺត្រូវការ ជាចាំបាច់ឱ្យមានឆន្ទៈនយោបាយដើម្បីអនុវត្តវា ។

***៤៤. ការទប់ស្កាត់ និងការកំណត់ភាពមិនប្រក្រតីចំពោះការប្រើប្រាស់ថវិកាឱ្យចំគោលដៅទាំងនៅផ្នែកគំរោង និងផ្នែកផលប័ត្ររួមនៅតែបន្ត ។*** វិធានការកាត់បន្ថយដែលពិពណ៌នានៅក្នុងកថាខ័ណ្ឌទី ៣០ ត្រូវតែអនុវត្តប្រកបដោយប្រសិទ្ធិភាព ។ ដើម្បីឱ្យដំណើរការនេះដើរទៅបាន ធនាគារពិភពលោក និងរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតយន្តការត្រួតពិនិត្យ និងវាយតំលៃនៅថ្នាក់គំរោង និងថ្នាក់ផលប័ត្រទាំងមូល ។

***៤៥. ការសម្របសម្រួលម្ចាស់ជំនួយ និងភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធ មានភាពរីកចំរើនច្រើន សំរាប់រយៈពេលបីឆ្នាំចុងក្រោយនេះ ហើយវាមានសារៈសំខាន់ណាស់ដែលចលករជាវិជ្ជមាននេះនៅតែបន្ត ។*** សមត្ថភាពក្នុងការនិយាយភាសាតែមួយចំពោះបញ្ហាគោលនយោបាយ ការដាក់ថវិការួមគ្នា និងការតឹមកិច្ចខិតខំប្រឹងប្រែងរបស់ម្ចាស់ជំនួយឱ្យខិតទៅកាន់តែជិតយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលកម្ពុជា បានលើកកំពស់ប្រសិទ្ធិភាពនៃសហគមន៍អ្នកផ្ដល់ជំនួយនៅកម្ពុជាយ៉ាងធំធេង ។ ការឈានទៅរកការចាប់ដៃគូដែលមិនមែនរដ្ឋាភិបាល ក៏មានភាពប្រសើរផងដែរសំរាប់ការចូលរួមជជែងអំពីគោលនយោបាយ ។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើឱ្យភាពជាដៃគូដើរទៅមុខយ៉ាងលឿននោះ វាត្រូវការពេលវេលា និងការបង្កើតតំលៃចំណាយលើការអនុវត្តកម្មវិធីរបស់ធនាគារពិភពលោក ។ កិច្ចខិតខំប្រឹងប្រែងនេះ ក៏ទាមទារឱ្យមានការប្ដេជ្ញាចិត្តខ្ពស់ និងការយល់ដឹងខ្លាំងប្រសិនបើចង់ឱ្យវាបន្តដើរទៅមុខទៀត ។

***៤៦. សេចក្ដីសន្និដ្ឋាន ក្នុងអំឡុងពេលដែលអភិបាលកិច្ចនៅតែចោទជាបញ្ហាប្រឈម ដំណើរការរីកចំរើនឈានទៅរកការទទួលបានលទ្ធផលតាមគោលដៅរបស់ CAS នៅកម្ពុជា គឺមាន ៣០ ភាគរយ នៃសូចនាករវឌ្ឍនភាពមធ្យមត្រូវបានបញ្ចប់ ហើយជាង ៤៣ ភាគរយនៃសូចនករនេះ គឺស្ថិតនៅលើគន្លងដ៏ត្រឹមត្រូវ ។*** សំរាប់ពេលខាងមុខ CAS នៅតែជាយុទ្ធសាស្ត្របន្តផ្ដោតទៅលើអភិបាលកិច្ចដដែល ។CAS ត្រូវបានស្នើសំរាប់ពន្យាពេលរហូតដល់ឆ្នាំ២០១១ ដោយតឹមទៅតាម NSDP ថ្មីរបស់រដ្ឋាភិបាល

និងក៏បង្កឱកាសឱ្យដៃគូអភិវឌ្ឍន៍ដ៏ទៃទៀតចូលរួមតាក់តែងជាមួយគ្នា ហើយអាចបញ្ចប់របៀបវារៈរបស់ខ្លួនដែលជាលទ្ធផលបង្កឡើងដោយបញ្ហាការប្រើប្រាស់ថវិកាមិនចំគោលដៅ ។ កម្មវិធីមានមហិច្ឆតាធំធេង ហើយក៏មានហានិភ័យដែរ ប៉ុន្តែបានចេញជាលទ្ធផលមួយចំនួននៅក្នុងប្រទេស ។

# ដំណើរការវឌ្ឍនភាពឆ្ពោះទៅរកគោលដៅរបស់ CAS

## គោលដៅទី១: លើកកំពស់ការអភិវឌ្ឍវិស័យឯកជនសំរាប់កាត់បន្ថយភាពក្រីក្រ

១. *បរិបទឆ្នាំ ២០០៥:* ភាពទន់ខ្សោយខាងលិខិតបទដ្ឋាននាំឱ្យអ្នកនាំចេញមានភាពស្មុគ្រស្មាញ តំលៃសំរាប់ធ្វើពាណិជ្ជកម្មខ្ពស់នាំឱ្យការប្រកួតប្រជែងមានកំរិត។ វិស័យផ្សេងៗ ក្រៅពីកាត់ដេរ និងទេសចរ ធ្វើឡើងដោយក្រុមហ៊ុនតូចៗ មិនផ្លូវការ និងមានកំរិតសំរាប់តែទីផ្សារក្នុងស្រុក ។ កំណើន មានភាពលំបាកដោយសារខ្វះស្ថាប័នសំរាប់សមាហរណកម្មទីផ្សារ កាត់បន្ថយហានិភ័យ ពង្រឹងកម្មសិទ្ធិបញ្ញា និងបរិយាកាសសំរាប់ពាណិជ្ជកម្មប្រសើរ ។ ក្របខ័ណ្ឌច្បាប់ និងស្ថាប័នមិនច្បាស់លាស់ និងការខ្វះខាតនៃសមត្ថភាពនិយតកម្ម បានរារាំងដល់វិស័យឯកជនសំរាប់ការវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ។

២. *លទ្ធផលរំពឹងទុក:* ផលលំបាកដែលទាក់ទិននឹងអភិបាលកិច្ចដើម្បីកំណើនត្រូវបានកាត់បន្ថយ ។ ស្ថាប័ននានាដែលសមាហរណកម្មក្រុមហ៊ុនថ្មីៗចូលទៅក្នុងចង្វាក់តំលៃអន្តរជាតិ ត្រូវបានបង្កើត ។ បង្កើនវិនិយោគឯកជននៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ និងបង្កើតតម្លាភាព និងគណនេយ្យភាពនៃភាពជាដៃគូរវាងសាធារណៈ/ឯកជននៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ។

៣. *វឌ្ឍនភាពនៅក្នុងប្រទេស:* ភាពជឿនលឿននៅក្នុងផ្នែកទាំងនេះគឺមានភាពចំរុះ មាន ៥០ ភាគរយ នៃសូចនាករមធ្យមនៃវឌ្ឍនភាពឆ្ពោះទៅរកលទ្ធផលនៃ CAS ត្រូវបានសំរេច ឬនៅលើគន្លងត្រឹមត្រូវ ហើយ ៤១ ភាគរយទៀត គឺមានភាពយឺតយ៉ាវ ។ ចំពោះកិច្ចសម្របសម្រួលពាណិជ្ជកម្ម មានចលនាទៅមុខយឺតៗ ឆ្ពោះទៅរកកម្មវិធីស្វ័យតភាពគយ (ASYCUDA) ដែលសាកល្បងនីតិវិធីគយស្វ័យតនៅក្នុងឯកសាររដ្ឋបាលតែមួយ (SAD) ដែលនឹងគ្រោងធ្វើឡើងនៅកំពង់ផែក្រុងព្រះសីហនុខែឧសភាឆ្នាំ ២០០៨ និងនៅទូទាំងប្រទេសនាឆ្នាំ ២០០៩ ។ ច្បាប់ពន្ធគយដែលជាមធ្យោបាយសំរាប់កំណែទំរង់គយ និងដើម្បីប្រតិបត្តិ ASYCUDA ត្រូវបានអនុម័តដោយសភាកាលពីឆ្នាំ ២០០៧ ហើយយុទ្ធសាស្ត្រសំរាប់គ្រប់គ្រងហានិភ័យត្រូវបានអនុម័ត និងការអនុវត្តកំពុងតែចាប់ផ្តើម ។ វឌ្ឍនភាពផ្សេងៗទៀត គឺមានដំណើរការទៅមុខ ដូចជា ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស ។ ចំពោះការលើកកំពស់ក្របខ័ណ្ឌច្បាប់សំរាប់វិនិយោគទុន និងការអភិវឌ្ឍវិស័យឯកជន ច្បាប់ស្តីអំពីអជ្ញាកណ្តាលពាណិជ្ជកម្ម និងច្បាប់ស្តីអំពីសម្បទាន ត្រូវបានអនុម័តដោយសភាកាលពីខែមីនាឆ្នាំ ២០០៦ និងខែកញ្ញាឆ្នាំ ២០០៧ ជាបន្តបន្ទាប់ ក៏ប៉ុន្តែការអនុវត្តទាំងនោះនៅមិនទាន់មានសកម្មភាពខ្លាំងក្លានៅឡើយ ។

៤. *តួនាទីរបស់ក្រុមធនាគារពិភពលោក:* ក្រុមធនាគារពិភពលោកផ្តោតការយកចិត្តទុកដាក់របស់ខ្លួនទៅលើកម្មវិធីអភិវឌ្ឍវិស័យឯកជននៅកម្ពុជា គឺការគាំទ្រការអភិវឌ្ឍបរិយាកាសវិនិយោគទុនតាមរយៈការសម្របសម្រួលពាណិជ្ជកម្ម និងការលើកកំពស់ក្របខ័ណ្ឌច្បាប់សំរាប់ការវិនិយោគ ។ កំណែទំរង់គោលនយោបាយនៅក្នុងផ្នែកទាំងពីរនេះ ត្រូវបានគាំទ្រតាមរយៈប្រតិបត្តិការកាត់បន្ថយភាពក្រីក្រ និងដើម្បីកំណើន (PRGO) លើកទីមួយ ដែលបានអនុម័តកាលពីខែកក្កដាឆ្នាំ ២០០៧ និងតាមរយៈគំរោងកិច្ចសម្របសម្រួលពាណិជ្ជកម្ម និងការប្រកួតប្រជែង ដែលកំពុងលើកកំពស់ការប្រកួតប្រជែងរបស់កម្ពុជា ដោយធ្វើឱ្យការនាំចេញ នាំចូលមានភាពងាយស្រួល និងកាត់បន្ថយតំលៃសំរាប់សកម្មភាពដែលទាក់ទិនទៅនឹងពាណិជ្ជកម្ម ។ IFC-MPDF បានរៀបចំការវាយតំលៃបរិយាកាសជំនួញថ្នាក់ខេត្ត នៅខេត្តចំនួន ១០ ហើយក្រុមធនាគារពិភពលោក នាពេលថ្មីៗនេះបានចាប់ផ្តើតការវាយតំលៃបរិយាកាសវិនិយោគទុន (ICA) ដើម្បីតាមដានលទ្ធផលចាប់តាំងពី ICA ដែលធ្វើឡើងកាលពីឆ្នាំ ២០០៤ និងដើម្បី កំណត់បញ្ហាថ្មីៗ និងរៀបចំសំរាប់ការគាំទ្រនានា នាពេលខាងមុខ។ ក្រុមធនាគារពិភពលោក ក៏បានដឹកនាំក្រុមការងារបច្ចេកទេសស្តីអំពីការអភិវឌ្ឍវិស័យឯកជន គាំទ្រវេទិកាវិស័យឯកជន/រដ្ឋាភិបាល និង ចូលរួមយ៉ាងសកម្មនៅក្នុងការពិភាក្សាស្តីអំពីបញ្ហាវិស័យឯកជនជាមួយរដ្ឋាភិបាល ម្ចាស់ជំនួយនានា និងវិស័យឯកជន។

## គោលដៅទី ២: លើកកំពស់ការគ្រប់គ្រងធនធានធម្មជាតិ

៥. *បរិបទឆ្នាំ ២០០៥:* ការខ្វះខាតការវាយតំលៃ ផែនទី ការចាត់ថ្នាក់ និងការចុះបញ្ជីដីរបស់រដ្ឋ (ដែលមានជិត ៨០ ភាគរយនៃផ្ទៃដីទាំងអស់) ឱ្យបានច្បាស់លាស់ បង្កឱ្យបានការទន្ទ្រានយកដីព្រៃ លក់ដី និងរឹបអូសយកដីធ្លីដោយខុសច្បាប់ ។ ការធ្លាក់ចុះនៃប្រព័ន្ធសម្បទានព្រៃឈើដែលធ្វើឡើងនៅថ្នាក់កណ្តាល ធ្វើឱ្យការគ្រប់គ្រងជាយុទ្ធសាស្រ្តមានការខ្វះខាត ។ មានការគ្រប់គ្រងមិនសមស្រប និងការត្រួតពិនិត្យតំបន់ការពារនៅខ្សោយ ។

៦. *លទ្ធផលរំពឹងទុក:* បង្កើនសាធារណៈជនឱ្យទទួលបានព័ត៌មានទាក់ទងនឹងស្ថានភាព និងការប្រើប្រាស់ដីរដ្ឋ និងការចូលរួមនៅថ្នាក់មូលដ្ឋាចំពោះការសំរេចនានាលើដីរដ្ឋ ។ បង្កើនចំនួនប្រជាជនកម្ពុជាក្រីក្រទទួលបានផលប្រយោជន៍ពីយន្តការផ្លូវការសំរាប់ការទទួលបាន និងមានសុវត្ថិភាពចំពោះភាពជាម្ចាស់នៃដីឯកជន ។ ពង្រឹងប្រព័ន្ធសំរាប់គ្រប់គ្រងធនធានព្រៃឈើ និងតំបន់ការពារ ។

៧. *វឌ្ឍនភាពនៅក្នុងប្រទេស:* ភាពជឿនលឿននៅក្នុងផ្នែកនេះគឺអាចទទួលយកបានដោយ ៦៥ ភាគរយនៃសូចនាករវឌ្ឍនភាពមធ្យមគឺបានបញ្ចប់ ឬនៅលើគន្លងត្រឹមត្រូវ ប៉ុន្តែបញ្ហាមួយចំនួននៅតែជាក្តីបារម្ភ ។ អនុក្រិតស្តីអំពីការគ្រប់គ្រង ដីរដ្ឋ និងដីសម្បទានសេដ្ឋកិច្ចត្រូវបានអនុម័ត ដោយរួមទាំងការផ្តល់សំរាប់ការពិនិត្យឡើងវិញ និងការលុចចោលដីសម្បទានសេដ្ឋកិច្ចណាដែលមិនដំណើរការ និងចាត់បែងចែកដីទាំងនោះប្រើប្រាស់ជាដីសម្បទានសង្គមកិច្ចសំរាប់អ្នកក្រីក្រវិញ ។ រាជរដ្ឋាភិបាលកម្ពុជាបានចែកប័ណ្ណកម្មសិទ្ធិដីធ្លីចំនួន ៨០០,០០០ សន្លឹក ហើយក៏បានចាប់ផ្តើតពិភាក្សាអំពីកម្មសិទ្ធិដីសហគមន៍ ដែលគ្រប់គ្រងដោយបងប្អូនជនជាតិភាគតិច ។ សកម្មភាពនានាត្រូវបានគេធ្វើឡើងដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងព្រៃឈើ ដោយ រួមទាំសកម្មភាពព្រៃឈើសហគមន៍: ពេលថ្មីៗនេះរាជរដ្ឋាភិបាលកម្ពុជាបានចេញច្បាប់ថ្មីស្តីអំពីតំបន់ការពារ ក្នុងគោលបំណង ដើម្បីផ្តល់ឱ្យបានភាពច្បាស់លាស់ដល់តួនាទីរបស់ស្ថាប័ននានា ការទទួលខុសត្រូវ និងកាតព្វកិច្ចដែលត្រូវបំពេញ ។ តែទោះជាយ៉ាងណាក៏ដោយ តម្លាភាពនៅក្នុង ELCS នៅតែត្រូវការលើកការកំពស់បន្ថែម ចំណែកឯកម្មវិធីដីសម្បទានសង្គមកិច្ចត្រូវការពន្លឿនឱ្យបានលឿនជាងនេះ ។ ការអនុវត្តច្បាប់នានាដែលគ្រប់គ្រងការទទួលបាន និងមានកម្មសិទ្ធិចំពោះធនធានធម្មជាតិ គឺនៅមានភាពយឺតយ៉ាវណាស់ ហើយភាពទន់ខ្សោយលើអភិបាលកិច្ចនៅក្នុងវិស័យព្រៃឈើនៅតែជាក្តីបារម្ភចំពោះអ្នកពាក់ព័ន្ធទាំងអស់ ។

៨. *តួនាទីរបស់ក្រុមធនាគារពិភពលោក:* ដើម្បីឱ្យមានភាពប្រសើរនៅក្នុងកិច្ចខិតខំប្រឹងប្រែងលើវិស័យដីធ្លី ព្រៃឈើ និងតំបន់អភិរក្សជីវៈសាស្រ្តចំរុះ ធនាគារពិភពលោកបានបង្កើតជាក្របខ័ណ្ឌការគ្រប់គ្រងធនធានធម្មជាតិមួយ ដែលស្វែងរកបញ្ហាប្រឈមធំៗ និងទាមទារឱ្យមានសកម្មភាពដើម្បីធ្វើឱ្យរបៀបវារៈនេះដំណើរការទៅមុខបាន ហើយធនាគារពិភពលោក នឹងប្រើប្រាស់ក្របខ័ណ្ឌនេះ នៅក្នុងការចូលរួមរបស់ខ្លួនក្នុងក្រុមការងារបច្ចេកទេសស្តីអំពីដីធ្លី កសិកម្ម ភាពក្រីក្រ បរិស្ថាន និងទឹក ។ កំណែទំរង់គោលនយោបាយក្នុងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវបានគាំទ្រតាមរយៈការសិក្សាបន្ថែម (ដោយ រួមទាំងការសិក្សាអំពីរចនាសម្ព័ន្ធកសិកម្ម និងការតាមដានបរិស្ថាន) កម្មវិធីកាត់បន្ថយភាពក្រីក្រ និងដើម្បីប្រតិបត្តិការកំណើន និងតាមរយៈប្រតិបត្តិការគាំទ្រវិនិយោគ និងការងារបច្ចេកទេសនានា ។ សំខាន់ជាគេនោះ គឺគំរោងគ្រប់គ្រងដីធ្លី និងរដ្ឋបាល (LMAP) ដែលបាន គាំទ្រឱ្យមានដំណើរការទៅមុខយ៉ាងលឿនចំពោះការផ្តល់កម្មសិទ្ធិដីធ្លី និងគំរោងគ្រប់គ្រងជីវៈសាស្រ្តចំរុះ និងតំបន់ការពារ ។ ទោះជាយ៉ាងណាក៏ដោយគំរោងទាំងពីរនេះ ក៏ដូចជាគំរោងបីផ្សេងទៀត ដែលគាំទ្រចំពោះការគ្រប់គ្រងធនធានធម្មជាតិ និងកសិកម្ម (មានគំរោង

---

[១] គំរោងគ្រប់គ្រងព្រៃសម្បទាន និងត្រួតពិនិត្យសាកល្បងនៅកម្ពុជា: ឯកសារវឌ្ឍនភាពស្តីអំពីការអនុវត្តនៃផែនការសកម្មភាពគ្រប់គ្រង (INSP/SecM2007-0004) ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៧ ។

គ្រប់គ្រងព្រៃសម្បទាន និងការត្រួតពិនិត្យសាកល្បង គំរោងស្តារឡើងវិញជាបន្ទាន់ និងគំរោងលើកកំពស់ផលិតភាពកសិកម្ម) ត្រូវបានស៊ើបអង្កេតដោយស្ថាប័នសុក្រិតភាព ហើយកំហុសឆ្គងលើលទ្ធកម្មគឺកើតមានឡើងចំពោះគំរោងទាំងបួននេះ ។ ពេលនោះគំរោង LMAP ត្រូវបានព្យួរជាបណ្តោះអាសន្នមួយរយៈ រហូតដល់មានវិធានការបន្ថែមត្រូវបានធ្វើឡើងសំរាប់កាត់បន្ថយហានិភ័យលើថវិកាទាំងនោះ ។គំរោងព្រៃឈើ ក៏ត្រូវបានត្រួតពិនិត្យដោយក្រុមអធិការកិច្ចផងដែរ ហើយដោយយោងទៅលើបទពិសោធន៍ដែលបានរៀនសូត្រពីដំណើរការរបស់ក្រុមអធិការកិច្ច[7] ធនាគារពិភពលោកបានធ្វើការយ៉ាងសកម្មដើម្បីស្វែងរកការឯកភាពពីរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា ចំពោះការគ្រប់គ្រងនាពេលអនាគតចំពោះវិស័យព្រៃឈើមុន នឹងមានការចូលរួមនៅក្នុងវិស័យនេះម្តងទៀត ។នៅក្នុង រយៈពេលបណ្តោះអាសន្ននោះ មូលនិធិ JSDF បានផ្តល់ថវិកាសំរាប់កសាងសមត្ថភាព និងការពង្រីកសកម្មភាពសហគមន៍ព្រៃឈើ ដល់អង្គការមិនមែនរដ្ឋាភិបាល មន្ត្រីរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន។

## គោលដៅទី ៣: ការលើកកំពស់ការផ្តល់សេវាកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៩. *បរិបទ ២០០៥:* ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺមានការលំបាកដោយសារតែចលនាសាច់ប្រាក់សុទ្ធនៃប្រព័ន្ធថវិកា ប្រព័ន្ធគណនេយ្យ និងរបាការណ៍នៅខ្វះខាត ។ លទ្ធភាពរបស់រដ្ឋាភិបាលក្នុងការផ្តល់សេវានានាមានការលំបាកដោយសេវាស៊ីវិលនៅទន់ខ្សោយ ។

១០. *លទ្ធផលរំពឹងទុក:* ពង្រឹងការប្រមូល និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយរៀបចំការលើកកំពស់សេវា និងកាត់បន្ថយអំពើពុករលួយ ។ ការគ្រប់គ្រងសេវាស៊ីវិល និងផ្តល់លាភការទៅនឹងស្នាដៃការងារដែលផ្តល់សេវាឱ្យបានប្រសើរ ។

១១. *វឌ្ឍនភាពនៅក្នុងប្រទេស:* ភាពជឿនលឿននៅក្នុងផ្នែកនេះគឺអាចទទួលយកបាន ដោយមាន ៥៦ ភាគរយ នៃសូចនាករលទ្ធផលមធ្យមត្រូវបានបញ្ចប់ ឬនៅលើគន្លងត្រឹមត្រូវ ។ មានភាពជឿនលឿនច្រើននៅក្នុងការធ្វើឱ្យប្រសើរលើកការចាត់ចែងសំរាប់ការងារថវិកា ការចាត់ថ្នាក់ថវិកា ការគ្រប់គ្រងសាច់ប្រាក់ និងគណនេយ្យធនាគារ ការត្រួតពិនិត្យហិរញ្ញវត្ថុ និងការគ្រប់គ្រងអន្តរកាល ។ ការទទួលខុសត្រូវចំពោះកិច្ចលទ្ធកម្មត្រូវបានធ្វើវិមជ្ឈការទៅតាមក្រសួងនានា ហើយការធ្វើឱ្យប្រសើរលើអនុក្រិតលទ្ធកម្ម និងការគាំទ្រការអនុវត្តច្បាប់ និងបទដ្ឋាននានាត្រូវបានអនុម័ត ហើយក៏មានវិធានការជាច្រើនទៀតសំរាប់បង្កើតការប្រកួតប្រជែងតម្លាភាព និងគណនេយ្យភាពនៅក្នុងដំណើរការលទ្ធកម្មក៏ត្រូវបានអនុម័តផងដែរ ។ ទាំងនេះបានចូលរួមចំណែកក្នុងការពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុទាំងមូល ដែលសូចនាករចុងក្រោយបានបង្ហាញថា ទំហំ ចំណាយពិត សរុបមាន ៥ ភាគរយ នៃថវិកា ។ចំណូលនៅតែមានកំណើន (ពីជាង ១០ ភាគរយ ទៅដល់ប្រមាណ ១២ ភាគរយ នៃ GDP សំរាប់ឆ្នាំ ២០០៧) ហើយបំណុលត្រូវលុបអស់យ៉ាងច្រើនផងដែរ ។

១២. គំនិតផ្តួចផ្តើមនៃប្រាក់លាភការដោយផ្អែកលើលទ្ធផលការងារ ត្រូវបានអនុវត្តនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគោលបំណងដើម្បីលើកកំពស់សេវាកម្មសាធារណៈ ប្រសិទ្ធិភាពការងារ និងសមត្ថភាព ។ ពេលនេះ ប្រព័ន្ធនេះកំពុងត្រូវបានពង្រីកយ៉ាងឆាប់រហ័សទៅដល់កំណែទំរង់យុទ្ធសាស្ត្រហិរញ្ញវត្ថុរបស់ដៃគូអភិវឌ្ឍន៍ក្នុងការលុបបំបាត់គំរោងផ្តល់ប្រាក់បៀវត្សបន្ថែមវិធីសាស្ត្ររបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ចំពោះការលើកទឹកចិត្ត និងការចាប់ផ្តើមដោះស្រាយបញ្ហានានា ដែលជាតំរូវការសំរាប់កំណែទំរង់សេវាស៊ីវិល។

១៣. *តួនាទីរបស់ធនាគារពិភពលោក:* ធនាគារពិភពលោកធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល និងជួយសម្របសម្រួលដៃគូអភិវឌ្ឍន៍នៅក្នុងក្រុមការងារបច្ចេកទេសស្តីអំពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងការតាក់តែងនិងអនុវត្តកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា (PFMRP) ។ ធនាគារពិភពលោកក៏បានគាំទ្រកម្មវិធី តាមរយៈគំរោងកាត់បន្ថយភាពក្រីក្រ និងប្រតិបត្តិការដើម្បីកំណើន (PRGO) និងគំរោងគណនេយ្យភាពគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ ។PFMRP គឺជាអភិក្រមរួមដំបូងនៅកម្ពុជា ហើយត្រូវបានទទួលស្គាល់ថាជាគំរូមួយសំរាប់ប្រសិទ្ធិភាពជំនួយជាសកល ។ ធនាគារពិភពលោកក៏បានលើកជាគំនិតពិភាក្សាស្តីអំពីការគ្រប់គ្រងចំណូលពីប្រេង និងស្តីអំពីគំនិតផ្តួចផ្តើមសំរាប់ តម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI) បញ្ចូលសង្គមស៊ីវិលនៅក្នុងការពិភាក្សាស្តីអំពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងជួយរដ្ឋាភិបាលនៅក្នុងការអនុម័តនិងពង្រីក MBPI ។ ការសិក្សាស្រាវជ្រាវស្តីអំពីការអង្កេតតាមដានការចំណាយសាធារណៈ នៅក្នុងវិស័យអប់រំ និងសុខភាព ក៏ដូចជាការសិក្សាស្តីអំពីការកំណែទំរង់សេវាស៊ីវិលសំរាប់គ្រូបង្រៀន ហើយជំនួយ ពីមូលនិធិមរតក បានគាំទ្រដល់ការពង្រឹងការត្រួតពិនិត្យរបស់រដ្ឋសភាលើថវិកាជាតិ ។

**គោលដៅទី ៤: គាំទ្រវិមជ្ឈការ និងលើកកំពស់ភាពជាដៃគូរបស់ប្រជាពលរដ្ឋសំរាប់អភិបាលកិច្ចល្អ**

១៤. *បរិបទឆ្នាំ ២០០៥:* ច្បាប់ គោលនយោបាយ ក្របខ័ណស្ថាប័នសំរាប់ដំណើរការវិមជ្ឈការនៅតែមានភាពផុយស្រួយ ។ ។ មូលនិធិនានាសំរាប់ថ្នាក់មូលដ្ឋានមិនគ្រប់គ្រាន់ និងមិនអាចរំពឹងទុកមុនបាន ។ យន្តការគណនេយ្យភាពខ្សោយ ធ្វើឱ្យមានការលំបាកសំរាប់ប្រជាពលរដ្ឋក្នុងការចូលរួមនៅក្នុងការធ្វើផែនការមូលដ្ឋាន និងការអនុវត្ត ក៏ដូចជាការទទួលបានព័ត៌មាន ។ សមត្ថភាពរបស់សង្គមស៊ីវិលនៅមានក៏រិតដើម្បីជំរុញឱ្យមានការទាមទារសំរាប់ធ្វើឱ្យប្រសើរលើការទទួលខុសត្រូវ និងការតាមដានការអនុវត្តរបស់រដ្ឋាភិបាល ។

១៥. *លទ្ធផលរំពឹងទុក:* លើកកំពស់គោលនយោបាយ និងក្របខ័ណ្ឌនីយតកម្មសំរាប់វិមជ្ឈការ និងការចូលរួមពីស៊ីវិល លើកកំពស់យន្តការ និងដំណើរការវិមជ្ឈការនៃធនធាន និងសេវាសំរាប់ក្រុមប្រឹក្សាឃុំ បង្កើនការការពារសិទ្ធិប្រជាពលរដ្ឋ និងការទទួលបានយុត្តិធម៌ និងព័ត៌មាន និងបង្កើនការចូលរួមរបស់ប្រជាជននៅក្នុងការជ្រើសរើសតំណាងរបស់ខ្លួននៅក្នុងដំណើរការគណនេយ្យភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

១៦. *វឌ្ឍនភាពនៅក្នុងប្រទេស:* ភាពជឿនលឿននៅក្នុងផ្នែកនេះ គឺគួរឱ្យចាប់អារម្មណ៍បំផុត ដោយមាន ៧១ ភាគរយនៃសូចនាករបានបញ្ចប់រឺស្ថិតនៅលើគន្លងដ៏ត្រឹមត្រូវ ។ ដោយស្របទៅនឹងគោលដៅវិមជ្ឈការនៃធនធានសំរាប់រដ្ឋាភិបាលថ្នាក់ក្រោមថវិកាសំរាប់ឃុំ/សង្កាត់នឹងគ្រោងកើនឡើងចំនួនពីរដងចាប់ពីឆ្នាំ ២០១០ ។ ការបោះឆ្នោតអាណត្តិទី២ឆ្នាំ ២០០៧ បានពង្រឹងមូលដ្ឋានសំរាប់ការលើកកំពស់គណនេយ្យភាពនៅថ្នាក់មូលដ្ឋាន ។ ក្រសួងមហាផ្ទៃបានទទួលជោគជ័យក្នុងការសាកល្បង "សេវាកម្មច្រកចេញចូលតែមួយ" និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុកដើម្បីពង្រឹងអភិបាលកិច្ចមូលដ្ឋាន ។ បន្ទាប់ពីមានការពន្យាពេលមួយរយៈមក រដ្ឋសភាជាតិបានអនុម័តច្បាប់អង្គការស្តីអំពីវិមជ្ឈការ និងវិសហមជ្ឈការកាលពីខែ មេសា ឆ្នាំ ២០០៨ ។ ប៉ុន្តែភាពរីកចំរើនសំរាប់លើកកំពស់ការទទួលបានព័ត៌មាន ព្រមទាំងការពង្រាងច្បាប់ស្តីអំពីការទទួលបានព័ត៌មាន គឺត្រូវបានពន្យាពេល ។ ចំណែកការចូលរួមពីសង្គមស៊ីវិលនៅក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្តគោលនយោបាយ គឺមានដំណើរទៅមុខយឺត។ ដោយសារពុំទាន់មានការចូលរួមយ៉ាងពេញទំហឹងជាមួយរដ្ឋាភិបាលកម្ពុជា ។

១៧. *តួនាទីរបស់ធនាគារពិភពលោក:* ធនាគារពិភពលោកបានផ្តល់ការគាំទ្រយ៉ាងពេញទំហឹងសំរាប់វិមជ្ឈការតាមរយៈ គំរោងការវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន (RILGP) ។ ធនាគារពិភពលោកបានធ្វើការសិក្សាជាបន្តបន្ទាប់ស្តីអំពីយុត្តិធម៌ សំរាប់អ្នកក្រ ក៏ដូចជាការសិក្សាអំពីការដោះស្រាយជំលោះនៅថ្នាក់ភូមិ និងការផ្តល់មតិយោបល់តាមរយៈក្រុមការងារបច្ចេកទេស ចំពោះគោលនយោបាយ និងយុទ្ធសាស្ត្រវិមជ្ឈការ ហើយក៏បានប្រមូលហិរញ្ញវត្ថុជាជំនួយឥតសំណងដើម្បី គាំទ្រការពិគ្រោះយោបល់រវាងរដ្ឋាភិបាល និងសង្គមស៊ីវិល ស្តីអំពីយុទ្ធសាស្ត្រវិមជ្ឈការ ក៏ដូចជាកម្មវិធីកសាងសមត្ថភាពសង្គមស៊ីវិលទាក់ទិនទៅនឹងការទទួលខុសត្រូវសង្គម ។

## គោលដៅទី៥: ការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រជាតិឆ្នាំ ២០០៦ -២០១០

១៨. *បរិបទឆ្នាំ ២០០៥:* ការខ្វះការសម្របសម្រួលជំនួយអភិវឌ្ឍន៍ផ្លូវការ និងការខ្វះខាតតួនាទីជាអ្នកដឹកនាំរបស់រដ្ឋាភិបាលនៅក្នុងជំនួយអភិវឌ្ឍផ្លូវការនេះ បាននាំទៅរកការបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍន៍ត្រួតគ្នា និងធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជា ចាយលើចំណាយអន្តរកាលមានតំលៃខ្ពស់ ។ មានព័ត៌មានតិចតួចណាស់ដែលអាចរកបានដើម្បីស្វែងយល់អំពីភាពក្រីក្រ ឬវិធី សាស្ត្រជាគោលនយោបាយសំរាប់កាត់បន្ថយភាពក្រីក្រ ។ ផលលំបាកជាក់ស្តែងដែលរារាំងចំពោះការអភិវឌ្ឍយេនឌ័រមិនត្រូវបានដោះស្រាយទេ ។

១៩. *លទ្ធផលនៃការរំពឹងទុក:* រដ្ឋាភិបាលបានផ្តោតទៅលើការពង្រឹងនៃការកាត់បន្ថយភាពក្រីក្រតាមរយៈការដាក់បញ្ចូលផែនការជាតិដោយមានការបង្កើតភាពជាម្ចាស់នៅក្នុងប្រទេស សមត្ថភាពសំរាប់ការអនុវត្ត ការតាមដាន និងការចូលរួម ។ ធនធានរដ្ឋាភិបាលកម្ពុជា និងជំនួយអភិវឌ្ឍន៍ផ្លូវការ រួមគ្នា រឹតរឹម ឱ្យមានប្រសិទ្ធិភាពជាមួយនឹងគោលដៅអភិវឌ្ឍន៍ជាតិ ។ វិសមភាពយេនឌ័រនឹងត្រូវបានដោះស្រាយដោយប្រាកដប្រជានៅក្នុងការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រដ្ឋាភិបាល ។

២០. *វឌ្ឍនភាពរបស់ប្រទេស:* ភាពលឿនលឿននៅក្នុងផ្នែកនេះគឺប្រសើរណាស់ ដោយមាន ៩២ ភាគរយ នៃសូចនាករត្រូវបានបញ្ចប់ ឬនៅលើគន្លងត្រឹមត្រូវ ។ រដ្ឋាភិបាលបានអនុម័ត NSDP នៅឆ្នាំ ២០០៦ ដោយជំនួសផែនការមួយ ដែលដឹកនាំដោយម្ចាស់ជំនួយជាមួយ នឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ក្រុមការងារបច្ចេកទេសសំរាប់ការរៀបចំផែនការ និងការកាត់បន្ថយភាពក្រីក្រ ផ្តល់វេទិកាមួយសំរាប់ឱ្យមានការពិភាក្សាជាទៀងទាត់ រវាងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលចំពោះការអនុវត្ត NSDP ហើយកាលពីពីរឆ្នាំមុន ក្រសួងផែនការបានតាត់តែង (ដោយមានការជួយគាំទ្រពីក្រុមការងារបច្ចេកទេស) ផែនការជាយុទ្ធសាស្ត្រមួយ ដើម្បីផ្តោតការយកចិត្តទុកដាក់ឡើងវិញរបស់ក្រសួង និងជួយកសាងសមត្ថភាពដើម្បីសម្របសម្រួលនៃការអនុវត្តការតាមដាន និងការវាយតំលៃនៃ NSDP ។ ក្រុមការងារបច្ចេកទេសក៏បាន ផ្តល់ជាវេទិកាសំរាប់ផ្ទេរការគាំទ្រពីខាងក្រៅទៅជាការគាំទ្រដោយក្រសួងនានា វិធីសាស្ត្រដោយផ្អែកលើកម្មវិធី ដោយដៃគូអភិវឌ្ឍន៍ដែលគាំទ្រក្រសួងផែនការ នឹងសម្រប សម្រួលជំនួយរបស់ពួកគេសំរាប់ជួយដល់ NSDP ។ ចំពោះសមភាពយេនឌ័រ ក៏មានភាពរីកចំរើនផងដែរ ដោយរួមទាំងការបង្កើន ការចូលរួមរបស់ស្ត្រីជាតំណាងនៅក្នុងក្រុមប្រឹក្សាឃុំពី ៨ ភាគរយ ទៅ ១៥ ភាគរយ នាពេលបោះឆ្នោតថ្នាក់ឃុំឆ្នាំ ២០០៧ ។

២១. *តួនាទីរបស់ធនាគារពិភពលោក:* ធនាគារពិភពលោក ដោយរួមជាមួយដៃគូអភិវឌ្ឍន៍នានា បានផ្តល់ការគាំទ្រ បច្ចេកទេស និងហិរញ្ញវត្ថុដល់ក្រសួងផែនការសំរាប់បង្កើត និងអនុវត្ត NSDP ដោយមានធនាគារពិភពលោក និង UNDP ដើរតួជាសហប្រធានសម្របសម្រួលរបស់ដៃគូអភិវឌ្ឍន៍នៅក្នុងក្រុមការងារបច្ចេកទេស ។ លើសពីនេះទៀត ការគាំទ្រដោយផ្ទាល់ទៅដល់ស្ថាប័នរដ្ឋាភិបាល និងដំណើរការនានាដែលទាក់ទិនទៅនឹង NSDP ធនាគារពិភពលោកបានជួយលើកកំពស់ចំណេះដឹងជាគន្លឹះសំរាប់អ្នក

ធ្វើគោលនយោបាយ និងអ្នកពាក់ព័ន្ធនានា តាមរយៈការវាយតំលៃភាពក្រីក្រឆ្នាំ ២០០៦ និង ការចែករំលែកកំណើនៈ របាយការណ៍សមធម៌ និងការអភិវឌ្ឍន៍ ។ ធនាគារពិភពលោកក៏បានផ្តល់ការគាំទ្រដល់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន តាមរយៈជំនួយ IDF ដោយមានគោលបំណងរួមសំរាប់គំរោងថវិកាយេនឌ័រ ក៏ដូចជា ជំនួយខ្នាតតូច ដាច់ដោយឡែកមួយសំរាប់សកម្មភាពផ្សព្វផ្សាយ ការបណ្តុះបណ្តាល សកម្មភាពតស៊ូមតិ ដោយរួមទាំងទស្សនកិច្ច សិក្សាសំរាប់ស្ត្រី ក្នុងភាពជាអ្នកដឹកនាំ សិក្ខាសាលាថ្នាក់តំបន់ស្តីអំពីការបញ្ជ្រាបយេនឌ័រនៅក្នុងប្រសិទ្ធិភាពជំនួយ និងសកម្មភាពផ្សព្វផ្សាយនៅកំរិតមូលដ្ឋាន ។

## គោលដៅទី៦: ការគាំទ្រចំពោះការសិក្សាវិភាគ និងការវិនិយោគដើម្បីសំរេចបាន CMDGs ការអភិវឌ្ឍធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធ

២២. *បរិបទឆ្នាំ២០០៥:* របៀបវារៈដែលដឹកនាំដោយម្ចាស់ជំនួយហាក់ដូចជាជាន់គ្នានៅក្នុងកម្មវិធីមួយចំនួននៅក្នុងវិស័យនានា ជាពិសេសវិស័យសុខភាព ហើយវិស័យផ្សេងៗទៀតបែជាមានគំលាតខ្លាំងទៅវិញ ។ ការចំណាយសំរាប់សេវាកម្មមានតំលៃខ្ពស់សំរាប់ប្រជាជនក្រីក្រ ហើយការផ្គត់ផ្គង់សេវា ជារឿយៗមិនបានទៅដល់អ្នកក្រីក្រនៅតាមសហគមន៍ទេ ។ សមត្ថភាព សំរាប់ផ្គត់ផ្គង់សេវាគឺនៅមានកំរិតទាប ។ វាមិនមានប្រព័ន្ធទទួលខុសត្រូវដើម្បីតាមដានគុណភាព និងការប្រតិបត្តិការងារទេ ។

២៣. *លទ្ធផលរំពឹងទុក:* គំលាតដែលមាននៅក្នុងគោលនយោបាយសេវាផ្គត់ផ្គង់គន្លឹះៗ និងការផ្តល់ជំនួយនៅក្នុងវិស័យ សុខាភិបាល និងអប់រំត្រូវបានបំពេញតាមរយៈវិធីសាស្ត្រសម្របសម្រួលស្តីអំពីផែនការអភិវឌ្ឍន៍ជាតិមួយ ។ យុទ្ធសាស្ត្រដែល រដ្ឋាភិបាលជាម្ចាស់មានភាពច្បាស់លាស់នៅក្នុងអនុវិស័យហេដ្ឋារចនាសម្ព័ន្ធ ដោយរួមទាំងក្របខ័ណ្ឌច្បាស់លាស់ សំរាប់ការគាំទ្រ ពីម្ចាស់ជំនួយ និងបង្កើនជំនួយអភិវឌ្ឍន៍ផ្លូវការ ។

២៤. *វឌ្ឍនភាពនៅក្នុងប្រទេស:* ភាពជឿនលឿនឆ្ពោះទៅរកលទ្ធផលរំពឹងទុករបស់ CAS នៅក្នុងផ្នែកនេះគឺមាន ទំហំធំធេង ដោយមាន ៤៣ ភាគរយនៃសូចនាករត្រូវបានបញ្ចប់ ហើយ ៥៧ ភាគរយទៀតគឺនៅលើគន្លងដ៏ត្រឹមត្រូវ ។ ទាំងនៅក្នុងវិស័យសង្គម និងហេដ្ឋារចនាសម្ព័ន្ធ គឺមានការរីកចំរើនគួរជាទីមោទនៈឆ្ពោះទៅរកយុទ្ធសាស្ត្រដែលរដ្ឋាភិបាលជាម្ចាស់ និងអាចឱ្យ ម្ចាស់ជំនួយគាំទ្រ ទាំងហិរញ្ញវត្ថុ និងបច្ចេកទេស ។ ក៏មានភាពរីកចំរើនស្មើរតែគ្រប់លទ្ធលដែលរំពឹងទុក សំរាប់ការអភិវឌ្ឍធនធានមនុស្ស ដូចជាអត្រាស្លាប់របស់ទារក អត្រាលូតលាស់ អត្រាប្រេវ៉ាឡង់ HIV និងអត្រាចុះឈ្មោះចូលរៀន ។ មានការទទួលបានសេវាសុខភាព អប់រំ និងសេវាហេដ្ឋារចនាសម្ព័ន្ធ ហើយក៏បានកំណត់គោលដៅសំរាប់ការផ្តល់ឧបត្ថម្ភនៅក្នុងវិស័យអប់រំ និងសុខភាព ។ មានធនធានច្រើនថែមទៀត ត្រូវបានវិនិយោគចំពោះវិស័យអាទិភាព ដូចជាការកាត់បន្ថយការស្លាប់របស់កុមារ និងម្តាយ ។ ការទទួលបានសេវាអប់រំ និង សុខភាព សំរាប់សហគមន៍ដែលងាយរងគ្រោះ ត្រូវបានពង្រីក ហើយការយល់ដឹងពីអ្នកប្រើប្រាស់ចំពោះសេវាសុខភាព និងអប់រំក៏បានប្រសើរផងដែរ ។ ក៏ប៉ុន្តែនៅមានសូចនាករមួយចំនួនទៀត ដូចជាការស្លាប់របស់ម្តាយ ឬអត្រាបោះបង់ចោលការសិក្សានៅតែជាក្តីបារម្ភ ។

២៥. *តួនាទីរបស់ធនាគារពិភពលោក:* ធនាគារពិភពលោកបានបន្តផ្តល់ការគាំទ្រដល់ការអភិវឌ្ឍ និងការអនុវត្ត យុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធិភាពនៅក្នុងវិស័យសង្គមតាមរយៈគំរោងគាំទ្រវិស័យសុខភាព និងគំរោងគាំទ្រវិស័យអប់រំដែលកំពុងតែដំណើរការ ក៏ដូចជាតាមរយៈការចូលរួមនៅក្នុងក្រុមការងារបច្ចេកទេសនានាផងដែរ ។ ការងាររៀបចំគំរោងសុខភាព មួយទៀត ដែលមានការគាំទ្រពីប្រទេសអូស្ត្រាលី និង DFID ជិតបញ្ចប់ហើយ ដើម្បីគាំទ្រយុទ្ធសាស្ត្រ និងកម្មវិធី នៅក្នុងវិស័យសុខភាព ក៏ដូចជាការធានាថា ប្រទេសកម្ពុជានឹងបានទទួលផលប្រយោជន៍ល្អចំពោះកម្មវិធីអប់រំសំរាប់ទាំងអស់គ្នា និងពីមូលនិធិកាតាលីកិសំរាប់គំនិតផ្តួចផ្តើម

(FTI) ។ ធនាគារពិភពលោកក៏បានធ្វើការអង្កេតតាមដានការចំណាយសាធារណៈ សំរាប់វិស័យសុខភាព និងវិស័យអប់រំ ដើម្បីលើកកំពស់ការកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងវិស័យទាំងនេះ ហើយក៏បានគាំទ្រដល់ការសិក្សាស្រាវជ្រាវនៅក្នុងវិស័យអប់រំផងដែរ ។

២៦. ផ្នែកហេដ្ឋារចនាសម្ព័ន្ធ ធនាគារពិភពលោកបានជួយលើការអភិវឌ្ឍនៅក្នុងយុទ្ធសាស្ត្រអនុវិស័យនានា តាមរយៈការសិក្សាស្រាវជ្រាវ (មានការពិនិត្យលើយុទ្ធសាស្ត្រវិស័យថាមពលបច្ចុប្បន្នភាពវិស័យដឹកជញ្ជូន យុទ្ធសាស្ត្រអនុវត្តសំរាប់គោលនយោបាយផ្គត់ផ្គង់ទឹកនៅទីក្រុង និងសេចក្តីសង្ខេបព័តិមានទាក់ទងនឹងប្រេង និងឧស្ម័ន) និងតាមរយៈក្រុមការងារបច្ចេកទេស ។ ធនាគារពិភពលោកក៏បានចូលរួមនៅក្នុងគំរោងវិនិយោគនានាដែលមានប្រយោជន៍ច្រើន ដល់អ្នកដែលត្រូវទទួលបានផងនេះ ។ តែទោះជាយ៉ាងណាក៏ដោយការព្យួរគំរោងហេដ្ឋារចនាសម្ព័ន្ធចំនួនពីរ គឺគំរោងហេដ្ឋារចនាសម្ព័ន្ធខេត្ត និងជនបទ និងគំរោងការផ្គត់ផ្គង់ទឹក និងអនាម័យតំបន់ជាយក្រុង និងខេត្តបានពន្យាពេលសំរាប់ការអនុវត្តនៅក្នុងហេដ្ឋារចនាសម្ព័ន្ធ ។ ការព្យួរទាំងនោះ ត្រូវបានលើកវិញកាលពីខែកុម្ភៈ ឆ្នាំ ២០០៧ ។

karyal yFnaKarBPBe l akRbcaenAkmCa
១១៣ មហាវិថីព្រះនរោត្តម
ទូរស័ព្ទ : (855 23) 213 538
ទូរសារ : (855 23) 210 373

mN l BtmansaFarN³
៧០ មហាវិថីព្រះនរោត្តម
ទូរស័ព្ទ : (855 23) 217 304
ទូរសារ : (855 23) 210 373

វេបសាយ : ជាភាសារខ្មែរ : www.worldbank.org.kh
ជាភាសារអង់គ្លេស : www.worldbank.org/kh